CBC

# របាយការណ៍ប្រចាំឆ្នាំ ២០២០

## ជម្រុញការប្រើប្រាស់ប្រព័ន្ធឌីជីថល និង វិភាគទិន្នន័យប្រកបដោយប្រសិទ្ធភាព



# មាតិកា


## សារពីប្រធានក្រុមប្រឹក្សាភិបាល
## សារពីប្រធាននាយកប្រតិបត្តិ

## ១. អំពី ស៊ីប៊ីស៊ី
- ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ
- យុទ្ធសាស្រ្តគោលដៅ
- ព្រឹត្តិការណ៍សំខាន់ៗ
- សារៈសំខាន់របស់ ស៊ីប៊ីស៊ី

## ២. អភិបាលកិច្ច
- រចនាសម្ព័ន្ធក្រុមហ៊ុន
- ភាគទុនិក
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រងក្រុមហ៊ុន

## ៣. ផលិតផល និងសេវាកម្ម
- ពីអាជីវកម្មទៅអតិថិជន (B2C)
- ពីអាជីវកម្មទៅអាជីវកម្ម (B2B)

## ៤. សកម្មភាពដែលបានធ្វើក្នុងឆ្នាំ ២០២០
- ផលិតផលថ្មីដែលត្រូវបានដាក់ឲ្យប្រើប្រាស់
- ពានរង្វាន់ឧត្តមភាពកំរិតពិភពលោក
- ការរក្សាទំនាក់ទំនងជាមួយសមាជិក
  - គណៈកម្មាធិការសមាជិកប្រតិបត្តិ
  - វគ្គបណ្តុះបណ្តាលសមាជិក
- សកម្មភាពបុគ្គលិក
  - ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក
  - ការផ្តល់រង្វាន់ និងការទទួលស្គាល់
  - ការរួបរួមគ្នាជាក្រុម
- ការប្តេជ្ញា និងទំនួលខុសត្រូវ
  - ការពិភាក្សាចែករំលែកចំណេះដឹងជាមួយអតិថិជន
  - វិញ្ញាបនបត្រកម្រិតមាសនៃការអនុលោមសារពើពន្ធ
  - ការពិភាក្សាពេលព្រឹក
  - កម្មវិធីវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោកឆ្នាំ ២០២០
  - កម្មវិធីនវាវត្តន៍បញ្ញាស
  - គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី
  - ការពង្រឹងអភិបាលកិច្ចនៃគ្រឹះស្ថានឥណទានជនបទ

## ៥. ស្ថានភាពជារួមនៃទីផ្សារឥណទាននៅប្រទេសកម្ពុជា
- សូចនាករសំខាន់ៗនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា
- ស្ថានភាពទីផ្សារឥណទានបុគ្គលនៅកម្ពុជា
- ស្ថានភាពទីផ្សារឥណទានក្រុមហ៊ុននៅកម្ពុជា



# សារពីប្រធាន
# ក្រុមប្រឹក្សាភិបាល

**លោកជំទាវ ជា សិរី**

ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល នាងខ្ញុំមានក្តីសោមនស្សរីករាយ សូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី សម្រាប់ឆ្នាំសារពើពន្ធ ២០២០។ នាងខ្ញុំតាក់តែងសារនេះឡើង អំឡុងពេលដែលសេដ្ឋកិច្ចពិភពលោកកំពុងទទួលរងផលប៉ះពាល់មិនធ្លាប់មានដោយសារជំងឺរាតត្បាតកូវីដ១៩ និងកំពុងសម្របខ្លួនទៅតាមរបត់សង្គមថ្មីខុសពីមុន។ ទោះបីជាស្ថានភាពក្នុងឆ្នាំ២០២០ មានភាពមិនប្រាកដប្រជាយ៉ាងនេះក្តី ស៊ីប៊ីស៊ី នៅតែអាចបន្តធ្វើប្រតិបត្តិការបានយ៉ាងរលូន ក្នុងការលើកកម្ពស់តម្លាភាពនៃទីផ្សារឥណទាន និងគ្រប់គ្រងហានិភ័យឥណទានក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

នៅពេលដែលជំងឺរាតត្បាតនេះបានចាប់ផ្តើមក្នុងប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការយ៉ាងទាន់ពេលវេលាក្នុងការអនុញ្ញាតឱ្យស្ថាប័នផ្តល់កម្ចីទាំងអស់ កែសម្រួលគោលនយោបាយនានា និងនីតិវិធីសម្រាប់ការរៀបចំឥណទានឡើងវិញ សំដៅធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និងការបន្ធូរបន្ថយនូវបន្ទុករបស់អ្នកខ្ចី។ ជាការឆ្លើយតប ស៊ីប៊ីស៊ី បានអនុម័តនូវវិធានការយ៉ាងសកម្ម ដើម្បីបង្កើតនិងដាក់ឱ្យប្រើប្រាស់នូវយន្តការមួយចំនួន ដូចជា យន្តការធ្វើសមាហរណកម្មដាក់បញ្ចូលព័ត៌មានឥណទានរៀបចំឡើងវិញចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជាដើម។

ចាប់ពីឆ្នាំ២០១២ មក ស៊ីប៊ីស៊ី បាននិងកំពុងផ្តល់នូវព័ត៌មានឥណទានប្រកបដោយតម្លាភាព និងមានភាពគ្រប់ជ្រុងជ្រោយសម្រាប់វិស័យសាធារណៈ និងឯកជន សំដៅគាំទ្រស្ថិរភាពវិស័យហិរញ្ញវត្ថុ និងធានាបាននូវកំណើនសេដ្ឋកិច្ចក្នុងប្រទេស។ ប្រតិបត្តិការរបស់ ស៊ីប៊ីស៊ី ដើរតួយ៉ាងសំខាន់ក្នុងការធានានូវកម្រិតនៃស្ថានភាពបំណុលពិតប្រាកដរបស់អ្នកខ្ចី និងអាចចូលរួមកាត់បន្ថយស្ថានភាពបំណុលវ័ណ្ឌក ដែលបញ្ហានេះមិនត្រឹមតែប៉ះពាល់ដល់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែក៏មានឥទ្ធិពលអវិជ្ជមានទៅដល់ស្ថាប័នហិរញ្ញវត្ថុ និងម្ចាស់ហិរញ្ញប្បទានផងដែរ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជា ចំពោះការជួយគាំទ្រលើបទប្បញ្ញត្តិ ដែលសម្រួលឱ្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជាមានភាពកាន់តែទូលំទូលាយឡើង។ ប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០២០ អនុញ្ញាតឱ្យយើងទទួលបានប្រភពព័ត៌មានថ្មីៗ និងសហការជាមួយអ្នកផ្តល់ទិន្នន័យច្រើនជាងមុន ខណៈរក្សាបាននូវគោលនយោបាយឯកជនភាពទិន្នន័យផងដែរ។ ជាមួយនឹងគោលការណ៍ណែនាំពីធនាគារជាតិនៃកម្ពុជា ស៊ីប៊ីស៊ី បានសម្របខ្លួនទៅនឹងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃទីផ្សារទាំងមូល ព្រមទាំងធានាបាននូវភាពជឿជាក់ និងទំនុកចិត្តពីសំណាក់ដៃគូគ្រប់មជ្ឈដ្ឋាន។

ដូច្នេះ ដើម្បីរក្សាបាននូវកំណើន ស្របនឹងការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ និងទំនោររបស់អតិថិជន ស៊ីប៊ីស៊ី បានដាក់ឱ្យប្រើប្រាស់នូវពិន្ទុឥណទានជំនាន់ថ្មី ដែលជួយសម្រួលដល់ការសម្រេចចិត្តផ្នែកឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងអាចឈានទៅដល់ការធ្វើការសម្រេចចិត្តផ្នែកឥណទានដោយស្វ័យប្រវត្តិ។

នៅក្នុងឆ្នាំ២០២០ ស៊ីប៊ីស៊ី បានធ្វើឌីជីថលភាវូបនីយកម្ម ដោយដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ី ដែលអនុញ្ញាតឱ្យប្រជាជនទាំងអស់ធ្វើការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ខ្លួន និងធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណពីចម្ងាយ។ ជាមួយនឹងការកើនឡើងនៃការប្រើប្រាស់ស្មាតហ្វូន សេវាហិរញ្ញវត្ថុឌីជីថល និងភាពប្រសើរឡើងនៃការទទួលបានសេវាអ៊ីនធើណេត ការណ៍នេះនឹងលើកកម្ពស់ការបណ្តុះឥរិយាបទទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះផងដែរ នាងខ្ញុំសូមសម្តែងការកោតសរសើរចំពោះការដឹកនាំរបស់ លោក អឿ សុធារ័ត្ន ប្រធាននាយកប្រតិបត្តិ ក៏ដូចជាបុគ្គលិក ស៊ីប៊ីស៊ី ទាំងអស់ ដែលមានភាពស្វាហាប់ និងឧស្សាហ៍ព្យាយាមខ្ពស់ ឈានទៅសម្រេចសមិទ្ធផល និងគោលដៅជាច្រើនគួរជាទីមោទនៈ។ នៅក្នុងឆ្នាំ២០២០ គណៈគ្រប់គ្រងក្រុមហ៊ុនបានដាក់ចេញនូវគំនិតផ្តួចផ្តើមថ្មីៗ និងព្យាយាមរក្សាតុល្យភាពរវាងបច្ចេកវិទ្យាហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគ និងការចំណាយប្រតិបត្តិការ ស្របពេលដែលត្រូវសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបែបថ្មីក្នុងបរិយាកាសការងារ និងអាជីវកម្ម។

ដោយឈរលើការចូលរួមចំណែកដ៏ធំធេងរបស់ស៊ីប៊ីស៊ីក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ស៊ីប៊ីស៊ី ទទួលបាននូវពានរង្វាន់ឧត្តមភាពក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានអតិថិជនទូទៅពី Global Business Outlook ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស។ ជាមួយនឹងក្រុមបុគ្គលិកដ៏មានសមត្ថភាពរបស់ ស៊ីប៊ីស៊ី បូកផ្សំនឹងភាពជាដៃគូរឹងមាំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនិងភាគីពាក់ព័ន្ធនានា នាងខ្ញុំជឿជាក់ថា យើងនឹងនៅតែបន្តរួមចំណែកសំខាន់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។ នាងខ្ញុំក៏ជឿជាក់យ៉ាងមុតមាំដែរថា តាមរយៈការផ្តោតសំខាន់លើទិន្នន័យ ការវិភាគ និងបច្ចេកវិទ្យា យើងអាចជួយដោះស្រាយបញ្ហារបស់ស្ថាប័នជាសមាជិក ក៏ដូចជាអតិថិជនទូទៅ និងសង្គមទាំងមូល ដើម្បីជួយគ្រប់គ្នាឱ្យសម្របខ្លួនទៅនឹងបរិបទសង្គមការងារថ្មី រក្សាស្ថិរភាពហិរញ្ញវត្ថុ និងបន្តធ្វើនវានុវត្តន៍ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗ។ នាងខ្ញុំ ព្រមទាំងសមាជិកក្រុមប្រឹក្សាភិបាលផ្សេងទៀត នឹងធ្វើកិច្ចការជាមួយនឹងគណៈគ្រប់គ្រងក្រុមហ៊ុនឱ្យកាន់តែជិតស្និទ្ធថែមទៀត ដើម្បីធានាបានថាក្រុមហ៊ុននៅតែមានភាពរឹងមាំតទៅពេលអនាគតខាងមុខទៀត។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ធនាគារិក និងសហការីនៃអាជីវកម្មទាំងអស់ ដែលតែងបានប្តេជ្ញាចិត្តយ៉ាងមុតមាំ និងបំពេញគ្រប់កិច្ចការងារយ៉ាងស្វាហាប់ជាទីបំផុត។ នាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអភិបាលផ្សេងទៀត ចំពោះការផ្តល់ជាដំបូន្មានក្នុងការដោះស្រាយបញ្ហាប្រឈមនានា។ ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិកទាំងអស់ចំពោះការគាំទ្រជានិច្ចជាកាល។

យើងប្តេជ្ញាបន្តដំណើរឆ្ពោះទៅមុខក្នុងការកសាងអាជីវកម្មមួយប្រកបដោយនិរន្តរភាពសម្រាប់សមាជិកជាដៃគូ និងភាគទុនិកគ្រប់រូប។



# សារពីប្រធាន
# នាយកប្រតិបត្តិ

**អឿ សុធារ័ត្ន**

ប្រធាននាយកប្រតិបត្តិ

ក្នុងឆ្នាំ២០២០ ពិភពលោកបានជួបនូវវិបត្តិសុខភាព ដែលធ្វើអោយមានឱនភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិ។ បើទោះបីជាមានបញ្ហាប្រឈមយ៉ាងណាក៏ដោយ ស៊ីប៊ីស៊ី នៅតែអាចបន្តប្រតិបត្តិការ និងបម្រើសេវាកម្មដល់សមាជិកយ៉ាងរលូន។ នាពេលកន្លងមក យើងបានដាក់ចេញការផ្តួចផ្តើមថ្មីៗជាច្រើន លើការវិភាគទិន្នន័យ និងការប្រើប្រាស់ប្រព័ន្ធឌីជីថលប្រកដោយប្រសិទ្ធភាព។ ដូចនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងក្នុងការបង្ហាញនូវសមិទ្ធិផលសំខាន់ៗប្រចាំឆ្នាំនេះដូចតទៅ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុន ស៊ីប៊ីស៊ី បានបម្រើដល់ស្ថាប័នហិរញ្ញវត្ថុ ដែលជាសមាជិកចំនួន ១៦៨ ក្នុងនោះរួមមានធនាគារពាណិជ្ជកម្ម ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យា និងគ្រឹះស្ថានឥណទានជនបទ។ ទោះបីជាទីផ្សារឥណទានមានកំណើនទាបដោយសារតែរជំងឺកូវីត១៩ ក៏ដោយ យើងនៅតែអាចបញ្ចេញបានរបាយការណ៍ឥណទានអតិថិជនជាង ៥ លានរបាយការណ៍ ដែលចំនួននេះទាបជាងឆ្នាំមុនប្រមាណ ៧.៥%។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានឥណទានរបស់យើង ផ្ទុកនូវប្រវត្តិឥណទានរបស់អតិថិជនជាង ៧ លាននាក់ ដែលតួលេខនេះស្មើនឹងជាង ៦០% នៃចំនួនប្រជាជនសកម្មសរុបក្នុងប្រទេស និងទិន្នន័យឥណទានក្រុមហ៊ុនរបស់សហគ្រាសជាង ២២,០០០ស្ថាប័ន ដែលបានរាយការណ៍ដោយស្ថាប័នហិរញ្ញវត្ថុ ៦២ ជាសមាជិក។ យើងបានរាយការណ៍ និងតាមដានអំពីឥណទានដែលរៀបចំឡើងវិញដោយសារផលប៉ះពាល់នៃជំងឺកូវីដ១៩ និងផ្តល់សេវាកម្មដោយឥតគិតថ្លៃពីការស្នើសុំប្រវត្តិឥណទានចំពោះឥណទានដែលរៀបចំឡើងវិញ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ គណនីប្រាក់កម្ចីជាង ២៦០,០០០ ត្រូវបានរៀបចំឡើងវិញ។

ក្នុងឆ្នាំនេះផងដែរ យើងបានដាក់ចេញនូវផលិតផលថ្មីចំនួនពីរ សម្រាប់ស្ថាប័នហិរញ្ញវត្ថុជាសមាជិកប្រើប្រាស់ក្នុងការគ្រប់គ្រងហានិយឥណទាន ដោយប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធឌីជីថល។ ផលិតផលទីមួយ គឺ ខេស្ករជំនាន់ថ្មី ដែលត្រូវបានបង្កើតឡើង ដោយបញ្ចូលបន្ថែមនូវនិន្នាការទីផ្សារ ដែលរួមបញ្ចូលព័ត៌មានវិជ្ជមាន និងអវិជ្ជមានស្តីពីប្រវត្តិឥណទានរបស់អ្នកខ្ចី។ ផលិតផលទីពីរ គឺឧបករណ៍វិភាគទិន្នន័យឆ្លាតវៃ ជំនាន់ទី២ ឬហៅថាឧបករណ៍វិភាគទិន្នន័យ ដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់ស្ថាប័នហិរញ្ញវត្ថុជាសមាជិក អាចវិភាគទៅលើលទ្ធផលនៃការគ្រប់គ្រងឥណទានរបស់ស្ថាប័នខ្លួនធៀបនឹងវិស័យទាំងមូលអោយបានកាន់តែទូលំទូលាយ និងស៊ីជម្រៅជាងមុន។

ដោយមានការកើនឡើងយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ទូរស័ព្ទស្មាតហ្វូន និងធនាគារចល័ត យើងបានបង្កើតកម្មវិធីទូរស័ព្ទស៊ីប៊ីស៊ី (CBC Mobile App) សម្រាប់ផ្តល់ភាពងាយស្រួល និងឆ្លាតវៃក្នុងការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការទទួលបានសេវាកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល។ យើងជឿជាក់ថា អាជីវកម្មនឹងមានការរីកចំរើនបានលុះត្រាតែយើងវិនិយោគលើធនធានមនុស្ស បង្កើនការពេញចិត្តចំពោះការបំពេញការងារ និងពង្រឹងសមត្ថភាពរបស់បុគ្គលិក ដើម្បីឲ្យពួកគាត់អាចបម្រើសេវាកម្មដល់សមាជិក និងសង្គមអោយកាន់តែប្រសើរជាងមុន។ យើងបានបន្តផ្តល់វគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍប្រកបដោយគុណភាព ដើម្បីបង្កើនសមត្ថភាពបុគ្គលិក និងបន្តនូវវប្បធម៌រីកលូតលាស់នៅក្នុងក្រុមហ៊ុន។

យើងបានទទួលពានរង្វាន់ “Excellence in Consumer Credit Reporting Award” ពី “Global Business Outlook” ដែលជាទស្សនាវដ្តីអាជីវកម្មអន្តរជាតិនៃចក្រភពអង់គ្លេសចំពោះការរួមចំណែកក្នុងការគ្រប់គ្រងហានិភ័យឥណទានក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការបំពេញចន្លោះនៃកង្វះខាតនូវព័ត៌មានគ្រប់ជ្រុងជ្រោយរវាងម្ចាស់ឥណទាន និងអ្នកខ្ចី។ លើសពីនេះទៅទៀត យើងក៏បានគាំទ្រ និងចូលរួមក្នុងកម្មវិធី “the World Fintech Festival” និងបានសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មី “តេជោ” (Techo Startup Centre) ក្នុងការជម្រុញកម្មវិធីនវានុវត្តន៍បញ្ច្រាស (the Reverse Innovation) ដើម្បីជួយដល់អ្នកដឹកនាំវ័យក្មេងជំនាន់ក្រោយ ដែលអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការវិភាគទិន្នន័យក្នុងការជួយដោះស្រាយនូវបញ្ហាអាជីវកម្មដ៏ស្មុគស្មាញ។

ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំ និងការឆ្ពោះទៅរកការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់យើង អាចឲ្យក្រុមហ៊ុនត្រៀមខ្លួនរួចជាស្រេច ទទួលយកនូវនវានុវត្តន៍ថ្មីៗ ដើម្បីជួយដល់ការវិភាពទិន្នន័យ និងការប្រើប្រាស់ទិន្នន័យក្នុងការសម្រេចដ៏ត្រឹមត្រូវនៅក្នុងប្រទេស។ ខ្ញុំមានក្តីរំភើបរីករាយ ក្នុងការបន្តដឹកនាំក្រុមការងារ ដើម្បីអនុវត្តន៍ផែនការធុរកិច្ចសម្រាប់ឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់ខាងមុខ។ ក្នុងឆ្នាំ២០២១ យុទ្ធសាស្រ្តអាទិភាពទីមួយរបស់យើង គឺការបង្កើនភាពចម្រុះនៃប្រភពទិន្នន័យ ដោយទាយយកផលប្រយោជន៍ពីប្រភពទិន្នន័យថ្មីៗ ដើម្បីអោយសមាជិករបស់យើងទទួលបាននូវឧបករណ៍ក្នុងការសម្រេចចិត្ត និងគ្រប់គ្រងហានិភ័យឥណទានប្រសើរជាងមុន។ ទន្ទឹមនឹងប្រភពទិន្នន័យថ្មីៗ យើងកំពុងតែបង្កើនសមត្ថភាពការវិភាគទិន្នន័យរបស់យើង ដើម្បីបន្តអភិវឌ្ឍរបាយការណ៍ឥណទាន និងសេវាកម្មបន្ថែម សម្រាប់ឆ្លើយតបនឹងតម្រូវការរបស់សមាជិក។

មុននឹងបញ្ចប់ ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ដើម្បីបង្ហាញពីការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការណែនាំដ៏មានតម្លៃរបស់ក្រុមប្រឹក្សាភិបាល ធនាគារជាតិ នៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការគាំទ្រ និងការសហការជាបន្តបន្ទាប់ពីសមាគមសំខាន់ពីរ គឺសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកដៃគូ និងអតិថិជនចំពោះការជឿទុកចិត្ត និងការគាំទ្រកន្លងមក។ ជាចុងក្រោយ ខ្ញុំសូមអរគុណនូវការប្តេជ្ញាចិត្តរបស់បុគ្គលិកទាំងអស់ដែលជាកម្លាំងចលករក្នុងការជំរុញការរីកចម្រើន និងការបោះជំហានទៅមុខជានិច្ចរបស់ក្រុមហ៊ុន ស៊ីប៊ីស៊ី។

# ១. អំពី ស៊ីប៊ីស៊ី

# បេសកកម្ម

- បម្រើសមាជិក និងអតិថិជនរបស់យើងជាមួយនឹងប្រព័ន្ធរបាយការណ៍ឥណទានពេញលេញទាំងរូបវន្តបុគ្គល និងនីតិបុគ្គល
- បង្កើតសេវាថ្មីៗ ដែលអាចជួយដោះស្រាយបញ្ហាអាជីវកម្មរបស់ស្ថាប័ន
- ជួយសម្រួលដល់ដំណើរការសម្រេចចិត្តតាមរយៈសមត្ថភាពក្នុងការវិភាគទិន្នន័យរបស់យើង



# ចក្ខុវិស័យ

- ជាក្រុមហ៊ុនឈានមុខគេ នៅក្នុងប្រទេសកម្ពុជាក្នុងការផ្តល់ទិន្នន័យ សម្រាប់ធ្វើការសម្រេចចិត្ត

# គុណតម្លៃ

# CREDIT

C

## រក្សាការសម្ងាត់

យើងគឺជាដៃគូដែលអាចទុកចិត្តបាន និងមានវិជ្ជាជីវៈព្រមទាំងសីលធម៌ខ្ពស់បំផុត ដែលធានាបាននូវរាល់ការសំងាត់នៃឯកជនភាព ទៅតាមតម្រូវការដោយច្បាប់។

R

## ទំនួលខុសត្រូវ

ការទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហារបស់អតិថិជន គឺជាកាតព្វកិច្ចរបស់បុគ្គលិកគ្រប់រូប។ យើងជំរុញ និងលើកទឹកចិត្តទៅលើបុគ្គលិកក្នុងការលើកឡើងនូវគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីបំពេញនូវតម្រូវការរបស់អតិថិជន ។

E

## ឧត្តមភាព

ឧត្តមភាព គឺជាទំនួលខុសត្រូវរួមមួយ រួមចំណែកដោយបុគ្គលិកម្នាក់ៗ។ ពួកយើងមានមានមោទនភាពចំពោះគុណភាពនៃការងាររបស់យើង ដើម្បីសម្រេចបាននូវឧត្តមភាព ហើយវាត្រូវបានឆ្លុះបញ្ចាំងតាមរយៈគុណភាពនៃដំណោះស្រាយដែលយើងអភិវឌ្ឍសម្រាប់អតិថិជនរបស់យើង និងតម្លៃដែលពួកគេទទួលពីផលិតផល និងសេវាកម្មរបស់យើង។

D

## សុវត្ថិភាពទិន្នន័យ

សុវត្ថិភាពទិន្នន័យ គឺជាមុខងារស្នូលរបស់ក្រុមហ៊ុន CBC។ យើងប្តេជ្ញានឹងខិតខំប្រឹងប្រែង ដើម្បីធានាថាទិន្នន័យគ្រប់ប្រភេទត្រូវបានរក្សាទុកនៅក្នុងបរិយាកាសមានសុវត្ថិភាព និងអនុលោមតាមតម្រូវការទិន្នន័យឯកជនភាព។

I

## សុចរិតភាព

សុចរិតភាព គឺជាគោលការណ៍ដ៏មានតម្លៃបំផុតរបស់យើង ហើយយើងរក្សានូវបទដ្ឋានសីលធម៌ខ្ពស់រាល់ការអនុវត្តការងាររបស់យើង។ យើងប្តេជ្ញាតាមដានយ៉ាងសកម្ម និងធ្វើឱ្យមានសុចរិតភាពទិន្នន័យខណៈពេលដែលវាត្រូវបានផ្តល់ ហើយនឹងដោះស្រាយនូវរាល់ការបញ្ហាផ្សេងៗរបស់អតិថិជនដោយការគោរព។

T

## ការធ្វើការជាក្រុម

យើងជឿជាក់ថាស្មារតីក្រុម គឺជាកត្តាដ៏សំខាន់ដែលជំរុញឱ្យមានភាពជោគជ័យ។ ដរាបណាយើងធ្វើការរួមគ្នា នោះលទ្ធភាពដែលអាចធ្វើបានគឺមិនមានដែនកំណត់ឡើយ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង គឺធំជាងកិច្ចខិតខំប្រឹងប្រែងផ្ទាល់ខ្លួន ហើយការអនុវត្តការងារតាមរបៀបនេះ អតិថិជនរបស់យើងត្រូវបានបម្រើយ៉ាងល្អបំផុត។

# យុទ្ធសាស្ត្រគោលដៅ

ចំណុចយុទ្ធសាស្ត្រចំនួន ៦ ជំរុញអាជីវកម្ម និងផែនការប្រតិបត្តិការរបស់យើង ដើម្បីពង្រឹងសមត្ថភាពក្នុងការប្រកួតប្រជែង បង្កើនឱកាសទីផ្សារថ្មី និងសម្រេចបាននូវគោលដៅរីកចំរើន ប្រកបដោយចីរភាព។

## 1. ប្រសិទ្ធភាពទីផ្សារឥណទាន

យើងផ្តោតលើការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយទៅម្ចាស់ឥណទាន និងអ្នកទទួលឥណទាន ដែលធ្វើឱ្យការវាយតម្លៃហានិភ័យឥណទាន និងការសម្រេចចិត្តកាន់តែងាយស្រួល និងលឿនជាងមុនសម្រាប់សមាជិកក៏ដូចជាអតិថិជនរបស់ពួកគេ។

## 2. បច្ចេកវិទ្យា និងសន្តិសុខ

យើងព្យាយាមនាំយកបច្ចេកវិទ្យាចុងក្រោយបំផុតដើម្បីពន្លឿនការច្នៃប្រឌិត និងការអភិវឌ្ឍផលិតផលថ្មី ការធ្វើសមាហរណកម្មជាមួយសមាជិក ឬដៃគូ ក៏ដូចជាជួយសម្រួលដល់អតិថិជនក្នុងការរក្សាទិន្នន័យ និងព័ត៌មាន ឱ្យមានសុវត្ថិភាព។

## 3. ប្រភពទិន្នន័យចម្រុះ

ការកំណត់ និងជ្រើសរើសយកប្រភពទិន្នន័យថ្មី មានសារៈសំខាន់ណាស់សម្រាប់ស៊ីប៊ីស៊ីដើម្បីជំរុញការអភិវឌ្ឍផលិតផលថ្មី និងឆ្លើយតបទៅនឹងតម្រូវការក្នុងការប្រើប្រាស់ទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្តក្នុងវិស័យហិរញ្ញវត្ថុ។

## 4. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុ

យើងលើកកំពស់តម្លាភាពទីផ្សារឥណទាន ដើម្បីពង្រីកលទ្ធភាពក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុ ក៏ដូចជាជួយឲ្យបុគ្គលម្នាក់ៗអភិវឌ្ឍឥរិយាបទទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុ និងទទួលបានឥណទានក្នុងលក្ខខណ្ឌសមរម្យ។

## 5. ទេពកោសល្យ និងវប្បធម៌ច្នៃប្រឌិត

យើងយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញរបស់បុគ្គលិកដើម្បីធានាថាពួកគេអាចអនុវត្តជំនាញស្របតាមតម្រូវការទីផ្សារដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

## 6. ដៃគូយុទ្ធសាស្ត្រ

យើងមានឆន្ទៈក្នុងការអភិវឌ្ឍកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រ និងបង្កើតភាពជាដៃគូដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុ។

# ព្រឹត្តិការណ៍សំខាន់ៗ

## ការវិវឌ្ឍនៃស៊ីប៊ីស៊ីៈ

### ២០២០




ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់ "កម្មវិធីទូរស័ព្ទស៊ីប៊ីស៊ី" (CBC Mobile App) ដែលជាកម្មវិធីឌីជីថលរួមបញ្ចូលគ្នាដំបូង បង្អស់ ដែលអាចឲ្យបុគ្គលម្នាក់ៗពិនិត្យមើលរបាយការណ៍ឥណទាន ពិន្ទុឥណទាន និងទទួលបានការជូនដំណឹងពីការតាមដានឥណទាន។ ស៊ីប៊ីស៊ី បានដាក់អោយប្រើប្រាស់ "ខេ ស្ករ" ជំនាន់ថ្មីសម្រាប់អតិថិជនទូទៅ និងសម្រាប់សមាជិកជាដៃគូ។ ស៊ីប៊ីស៊ី ក៏បានដាក់ឲ្យប្រើប្រាស់សេវាវិភាគទិន្នន័យជំនាន់ថ្មី (Data Analytics Report) ។ ស៊ីប៊ីស៊ី បានទទួលពាន រង្វាន់ "Excellence in Consumer Credit Reporting" ពី "Global Business Outlook"

### ២០១៨




ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់នូវសេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការស្នើសុំរបាយការណ៍ឥណទានតាមរយៈការសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី និងធនាគារអេស៊ីលីដា ភីអិលស៊ីក្នុងការផ្តល់សេវានេះនៅតាមសាខារបស់ស្ថាប័នទាំងពីរ

### ២០១៩




ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់របាយការណ៍ឥណទានក្រុមហ៊ុនជាផ្លូវការ។ ស៊ីប៊ីស៊ី ក៏បានរៀបចំសិក្ខាសាលាស្តីពី ប្រព័ន្ធចែករំលែកឥណទាននៅកម្ពុជា និងការបង្កើតគំរូពិន្ទុឥណទានដល់មន្ត្រីជាន់ខ្ពស់មកពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធនានា

### ២០១៧




ស៊ីប៊ីស៊ី បានប្រារព្ធខួបគម្រប់ ៥ឆ្នាំ និងផ្តល់ពានរង្វាន់ដល់សមាជិករបស់ខ្លួន ដែលបានបង្ហាញស្នាដៃល្អ ក្នុងប្រតិបត្តិការជាមួយ ស៊ីប៊ីស៊ី និងបានចូលរួមចំណែកក្នុងវិស័យហិរញ្ញវត្ថុ។ ស៊ីប៊ីស៊ី បានរួមចំណែកលើកកម្ពស់ចំណាត់ថ្នាក់ប្រទេសកម្ពុជាដូចបង្ហាញក្នុងរបាយការណ៍របស់ធនាគារពិភពលោក ប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ៧ ជាប្រទេសដែលមានភាពងាយក្នុងការទទួលបានឥណទាន

# ២០១៦



ស៊ីប៊ីស៊ី មានស្ថាប័នសមាជិកសរុបចំនួន ១៣២ រួមមានធនាគារពាណិជ្ជកម្មចំនួន៣៧ ធនាគារឯកទេសចំនួន១៣ គ្រឹះស្ថានមីក្រូហិរញ្ញទទួលប្រាក់បញ្ញើចំនួន៧ មីក្រូហិរញ្ញវត្ថុចំនួន៦០ ក្រុមហ៊ុនភតិសន្យាចំនួន១០ និងគ្រឹះស្ថានឥណទានជនបទចំនួន៥។ ក្នុងឆ្នាំនេះផងដែរ ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់សេវាមួយថ្មីទៀត ដែលហៅថាដំណោះស្រាយអាជីវកម្មតាមតម្រូវការ ដែលជាសេវាវិភាគទិន្នន័យមានភាពបត់បែនស្របតាមតម្រូវការរបស់សមាជិក

# ២០១៥




ស៊ីប៊ីស៊ី បានបង្កើតបន្ថែមនូវសេវា ខេ ស្ករ (ខ្មែរ ស្ករ) ដែលជាសេវាកម្មមួយអាចជួយដល់ស្ថាប័នសមាជិកវាយតម្លៃទៅលើកម្រិតហានិភ័យនៃការស្នើសុំឥណទានរបស់បុគ្គលម្នាក់ៗ និងព្យាករណ៍ទៅលើលទ្ធភាពនៃការអាក់ខានសងត្រឡប់មកវិញ

# ២០១៤




ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់នូវដំណោះស្រាយអាជីវកម្មសំខាន់ៗចំនួន ៣ប្រភេទបន្ថែមសម្រាប់ស្ថាប័នជាសមាជិក រួមមានរបាយការណ៍វិភាគទិន្នន័យ សេវាតាមដានឥណទាន និងសេវាត្រួតពិនិត្យឥណទាន

# ២០១៣

**46th**

បន្ទាប់ពីស៊ីប៊ីស៊ី បានដំណើរការ១ឆ្នាំ ចំណាត់ថ្នាក់របស់ប្រទេសកម្ពុជានៅក្នុងរបាយការណ៍របស់ធនាគារពិភពលោកស្តីអំពីភាពងាយស្រួលក្នុងការទទួលបានឥណទាន មានភាពរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយទទួលបានការផ្លាស់ប្តូរចំនួន ៤៦ ចំណាត់ថ្នាក់ ដែលបានចុះពីលេខរៀងទី៩៦ ក្នុងឆ្នាំ២០១២ មកកាន់លេខរៀនទី ៥៤ ក្នុងឆ្នាំ២០១៣

# ២០១២

**ដំណើរការជាផ្លូវការ**

ឆ្នាំនេះជាទំព័រប្រវត្តិសាស្ត្រនៃក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា ដែលបានចាប់ផ្តើមដំណើរការជាផ្លូវការនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃវិស័យហិរញ្ញវត្ថុរបស់កម្ពុជា និងដំណើរការទីផ្សារឥណទានប្រកបដោយតម្លាភាព

# សារៈសំខាន់របស់ ស៊ីប៊ីស៊ី

## ជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមួយ ដើម្បីជួយបង្កើតទីផ្សារឥណទានប្រកបដោយតម្លាភាព និងប្រសិទ្ធភាព

តាមរយៈការប្រើប្រាស់ដំណោះស្រាយរបស់ ស៊ីប៊ីស៊ី ប្រជាពលរដ្ឋ និងស្ថាប័នឯកជនទាំងអស់អាចទទួលបានអត្ថប្រយោជន៍ជាច្រើន ដោយបុគ្គលម្នាក់ៗអាចទទួលបានសក្តានុពលកាន់តែប្រសើរឡើងនៅពេលពួកគាត់ដឹងអំពីប្រវត្តិឥណទានផ្ទាល់ខ្លួន រីឯស្ថាប័នហិរញ្ញវត្ថុក៏អាចគ្រប់គ្រងការប្រើប្រាស់ឥណទានរបស់ពួកគាត់កាន់តែល្អប្រសើរឡើង និងប្រកបដោយប្រសិទ្ធភាព។ កត្តាទាំងនេះ ជួយជំរុញព្រះរាជាណាចក្រកម្ពុជាទទួលបានភាពរីកចម្រើនក្នុងវិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយស្ថិរភាព។

### សម្រាប់អតិថិជន

**1**

បង្កើនភាពងាយស្រួលក្នុងការទទួលបានឥណទានជាមួយអត្រាការប្រាក់សមរម្យអាស្រ័យលើប្រវត្តិឥណទាន និងលទ្ធភាពសងកម្ចីរបស់អតិថិជន។

**2**

បង្កើនប្រសិទ្ធភាពក្នុងការវាយតម្លៃឥណទានដែលជួយពន្លឿនដំណើរការអនុម័តឥណទាន ហើយក៏ជួយឲ្យអតិថិជនអាចស្វែងរកប្រាក់កម្ចីលឿនជាងមុន។

**3**

អតិថិជនក៏មានជម្រើសក្នុងការស្នើសុំឥណទានពីអ្នកផ្តល់កម្ចីផ្សេងៗគ្នា ដែលជួយជម្រុញឲ្យមានការប្រកួតប្រជែង និងបង្កើតនូវផលិតផលឥណទានថ្មីៗ។

**4**

ជួយសម្រួលដល់អតិថិជន ដែលធ្លាប់មានប្រវត្តិឥណទានមិនល្អក្នុងការស្តារប្រវត្តិឥណទានទាំងនោះឡើងវិញ ហើយអាចនឹងស្វែងរកប្រាក់កម្ចីក្នុងអត្រាការប្រាក់សមរម្យ។

## សម្រាប់វិស័យហិរញ្ញវត្ថុ

### 1

ជួយពង្រីក និងធ្វើឲ្យមានភាពស្មើភាពគ្នាក្នុងការទទួលបានឥណទានតាមរយៈការកាត់បន្ថយនូវគម្លាតព័ត៌មានរវាងអ្នកខ្ចីប្រាក់ និងអ្នកផ្តល់កម្ចី ហើយអតិថិជនល្អៗអាចទទួលបានភាពងាយស្រួលជាងមុន និងការចំណាយទៅលើឥណទាន កាន់តែទាប។

### 2

ជួយធ្វើឲ្យឥណទានមានភាពល្អប្រសើរជាងមុនតាមរយៈការជួយឲ្យអ្នកផ្តល់កម្ចីអាចវាយតម្លៃពីហានិភ័យឥណទានបានសុក្រឹតជាងមុន និងបង្កើនគុណភាពផលប័ត្រឥណទាន។

### 3

ការការពារពីបំណុលលើសលុប តាមរយៈការផ្តល់នូវព័ត៌មានលម្អិតដល់អ្នកផ្តល់កម្ចីឲ្យស្វែងយល់កាន់តែប្រសើរអំពីបំណុលសរុបរបស់អតិថិជន ហើយអាចវាយតម្លៃពីលទ្ធភាពសងបំណុលត្រឡប់វិញ។

### 4

ជួយបង្កើនប្រាក់ចំណេញតាមរយៈប្រព័ន្ធផ្តល់ពិន្ទុឥណទាន និងការសម្រេចចិត្តស្វ័យប្រវត្តិដែលជួយកាត់បន្ថយការចំណាយប្រតិបត្តិការក្នុងការផ្តល់កម្ចី។

### 5

ជួយធ្វើឲ្យវិស័យហិរញ្ញវត្ថុ មានស្ថិរភាព ដោយផ្តល់នូវភាពវិជ្ជមាន និងប្រសិទ្ធភាពសម្រាប់គាំទ្រដល់ការគ្រប់គ្រងធនាគារ និងការតាមដានហានិភ័យជាប្រព័ន្ធ។

### 6

បង្កើនភាពប្រកួតប្រជែង និងជម្រុញការផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវ។



# ២. អភិបាលកិច្ច

# រចនាសម្ព័ន្ធក្រុមហ៊ុន



# ភាគទុនិក

រចនាសម្ព័ន្ធភាគទុនិកនៃក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា គឺជាការប្រមូលផ្តុំនៃក្រុមហ៊ុនជាតិ និងក្រុមហ៊ុនអន្តរជាតិ ដែលក្រុមហ៊ុនទាំងនេះមានគោលបំណងរួម តែមួយគត់ គឺដើម្បីបង្កើតនូវក្រុមហ៊ុនរបាយការណ៍ឥណទានឯកជន ចំណាត់ថ្នាក់ពិភពលោកមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើនេះ រចនាសម្ព័ន្ធភាគទុនិក គឺមានលក្ខណៈងាយស្រួល ពីព្រោះភាគទុនិករបស់ក្រុមហ៊ុន ស៊ីប៊ីស៊ី មានតែពីរគត់។

## ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ហូលឌីង (ខេមបូឌា) អិលធីឌី

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ហូលឌីង (ខេមបូឌា) ខូ អិលធីឌី ជាក្រុមហ៊ុនមួយបានចុះបញ្ជីយ៉ាងត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាន់កាប់ភាគទុន ៥១% នៅក្នុងក្រុមហ៊ុន ស៊ីប៊ីស៊ី។ ក្រុមហ៊ុនមួយនេះ ដែលហៅកាត់ថា CBHC តំណាងឲ្យវិស័យធនាគារទាំងអស់នាពេលនោះ ដែលភាគទុនទាំងនោះរួមមាន៖

- សមាគមធនាគារនៅកម្ពុជា
- សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
- ធនាគារអេស៊ីលីដា ភីអិលស៊ី
- ធនាគារសហពាណិជ្ជក.អ
- ធនាគារពាណិជ្ជទីមួយ

## ក្រុមហ៊ុន EQUIFAX CAMBODIA HOLDINGS PTE. LIMITED.

ក្រុមហ៊ុន Equifax Cambodia Holdings Pte. Limited. ជាក្រុមហ៊ុនមួយបានចុះបញ្ជីយ៉ាងត្រឹមត្រូវនៅប្រទេសសិង្ហបូរី ហើយបានបង្កើតឡើងនាឆ្នាំ ២០១០ នៅក្នុងគោលបំណងតែមួយគត់ គឺដើម្បីគ្រប់គ្រងភាគទុន ៤៩% នៅក្នុងក្រុមហ៊ុន ស៊ីប៊ីស៊ី ។ ក្រុមហ៊ុន Equifax Cambodia Holdings Pte. Limited. ឬហៅកាត់ថា ECH គឺជាក្រុមហ៊ុនវិនិយោគរួមគ្នាមួយ រវាងក្រុមហ៊ុនដៃគូយុទ្ធសាស្ត្រពីរ ដែលជាក្រុមហ៊ុនបង្កើតក្រុមហ៊ុនរបាយការណ៍ឥណទានជាសកល។ ក្រុមហ៊ុនដៃគូយុទ្ធសាស្ត្រទាំងពីរនោះគឺ៖ (១) ក្រុមហ៊ុន Credit Bureau Asia Holdings Pte. Ltd ជាក្រុមហ៊ុនចុះបញ្ជីនៅប្រទេសសិង្ហបូរី និង (២) ក្រុមហ៊ុន Equifax Inc. ជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងសហរដ្ឋអាមេរិច ។



# ក្រុមប្រឹក្សាភិបាល





# លោកជំទាវ ជា សិរី

## ប្រធានក្រុមប្រឹក្សាភិបាល

លោកជំទាវ ជា សិរី គឺជាឧបការីទេសាភិបាលមួយរូប នៃធនាគារជាតិនៃកម្ពុជា។ ដោយមើលឃើញកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ លោកជំទាវបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល សំដៅលើកកម្ពស់ឯករាជ្យភាពលើសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុនៅកម្ពុជា។ ក្រោមការដឹកនាំរបស់លោកជំទាវ នវានុវត្តន៍លើឧបករណ៍គោលនយោបាយជាច្រើនត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍទីផ្សារអន្តរធនាគារ និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។ លោកជំទាវ ក៏ជាសមាជិកក្នុងគណៈកម្មាធិការជាច្រើន ដែលដើរតួនាទីជំរុញការអនុវត្តគោលនយោបាយ នៅក្នុងវិស័យធនាគារ និងនៅកម្រិតថ្នាក់ជាតិផងដែរ។ ក្នុងតួនាទីជាប្រធានគណៈកម្មាធិការប្រតិបត្តិការសភាផាត់ទាត់ជាតិ លោកជំទាវបានដឹកនាំគម្រោង “បាគង” ដែលជាគំនិតផ្តួចផ្តើមមួយរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការស្វែងរក និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធទូទាត់ទំនើបថ្មី ដែលប្រើប្រាស់នូវបច្ចេកវិទ្យាប្លុកឆេន (Blockchain)។

លោកជំទាវជាសមាជិកក្រុមប្រឹក្សាអន្តរជាតិនៃវិទ្យាស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុសកល និងជាសមាជិកក្រុមប្រឹក្សាអាស៊ីអាគ្នេយ៍នៃធនាគារស្ត្រីពិភពលោកផងដែរ។ កាលពីឆ្នាំ ២០១៩ លោកជំទាវត្រូវបានជ្រើសរើសជាអ្នកដឹកនាំវ័យក្មេងពិភពលោកមួយរូប ក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក។ លើសពីនេះ លោកជំទាវក៏ជាសមាជិកនៃសម្ព័ន្ធអភិបាលកិច្ចរូបិយប័ណ្ណឌីជីថល និងជាគណៈកម្មាធិការប្រឹក្សានៃការទូទាត់តាមប្រព័ន្ធឌីជីថល សម្រាប់គម្រោងធុរកិច្ចនិងពាណិជ្ជកម្មផងដែរ។

លោកជំទាវ ជា សិរី ជា Senior Fellow នៅសាលាគោលនយោបាយសាធារណៈ លី គ្វាន់យូ នៃប្រទេសសឹង្ហបុរី និងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យ Adelaide នៃប្រទេសអូស្ត្រាលី។



## លោក គា បូរាណ

**អភិបាល**

លោក គា បូរាណ ជាថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលមានបទពិសោធន៍ជាច្រើនក្នុងការដឹកនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បច្ចុប្បន្ន លោកកំពុងបម្រើការងារក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាប់ចំណាប់ថ្នាក់ទី១ ដែលមានអតិថិជនច្រើនបំផុតក្នុងប្រទេសកម្ពុជា។

លោកបានចូលបម្រើការនៅអេអឹមខេអស់រយៈពេលជាង១០ឆ្នាំមកហើយចាប់តាំងពីឆ្នាំ២០០៤មក ដោយលោកបានកាន់តំណែងជាថ្នាក់ដឹកនាំជាច្រើន ដើម្បីចូលរួមអភិវឌ្ឍគ្រឹះស្ថាន រួមមានជាប្រធាននាយកហិរញ្ញវត្ថុ និងជាអនុប្រធាននាយកប្រតិបត្តិ។ មុនពេលដែលលោកចូលរួមជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ លោកបានបម្រើការងារនៅ World Relief Cambodia/CREDIT ក្នុងនាមជានាយកហិរញ្ញវត្ថុ។

លោក គា បូរាណ បានបញ្ចប់បរិញ្ញបត្រគ្រប់គ្រងពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ និងទទួលបានសញ្ញាបត្រ ACCA (Association of Chartered Certified Accountants)។ លោកបានក្លាយជាសមាជិករបស់ ACCA តាំងពីឆ្នាំ ២០០៨ មកម្ល៉េះ។



## លោក RAYMOND SIA SAY GUAN

**អភិបាល**

លោក RAYMOND Sia បច្ចុប្បន្ន មានតួនាទីជាប្រធាននាយកប្រតិបត្តិ/នាយកប្រតិបត្តិនៃធនាគារកាណាឌីយ៉ា ក.អ.។ មុនពេលចូលបំរើការធនាគារកាណាឌីយ៉ា ក.អ. លោក RAYMOND Sia បានបម្រើការក្នុងតួនាទីគ្រប់គ្រង និងដឹកនាំជាន់ខ្ពស់ជាច្រើនជាមួយនឹងធនាគារក្នុងស្រុក និងធនាគារអន្តរជាតិ នៅប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាម ដែលក្នុងនោះរួមមាន ធនាគារសាធារណៈ ធនាគារ Standard Chartered (ប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាម) និងធនាគារ Hong Leong នៅប្រទេសវៀតណាម ដែលលោកជាប្រធានប្រតិបត្តិ/អគ្គនាយក។

លោក RAYMOND Sia បានចាប់ផ្តើមអាជីពក្នុងវិស័យធនាគារ ជាអ្នកហាត់ការបន្ទាប់ពីបញ្ចប់ការសិក្សាជាមួយធនាគារសាធារណៈនៅប្រទេសម៉ាឡេស៊ីដែលគាត់បានចំណាយពេល១១ឆ្នាំក្នុងតួនាទីផ្សេងៗគ្នា ដូចជាប្រធានផ្នែកភាគហ៊ុន និងទីផ្សារមូលធន និងជាប្រធានដំណើរការឥណទាន។

នៅធនាគារ Standard Chartered លោក RAYMOND Sia មានតួនាទីដឹកនាំផ្សេងៗ ចាប់ពីនាយកសាជីវកម្មក្នុងស្រុក រហូតដល់ប្រធានក្រុមហ៊ុនសាជីវកម្មសាកល ដោយមុខតំណែងចុងក្រោយរបស់លោក គឺជាប្រធានធនាគារខ្នាតតូច និងមធ្យម និងជានាយកទូទៅ/នាយកប្រតិបត្តិនៃសាខាហាណូយ ។

លោក RAYMOND Sia មានបទពិសោធន៍ជាង ២៥ឆ្នាំ ក្នុងតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើន ក្នុងវិស័យធនាគារ រតនាគារ និងសេវាកម្មហិរញ្ញវត្ថុ នៅប្រទេសកម្ពុជា ម៉ាឡេស៊ី និងវៀតណាម។



## លោក សឹង ផន

**អភិបាល**

លោក សឹង ភន ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ជាប្រធានផ្នែកឥណទាន និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងឥណទាននៃធនាគារ អេស៊ីលីដា ភីអិលស៊ី។ លោក ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការសវនកម្ម នៅធនាគារអេស៊ីលីដា ក្នុងប្រទេសឡាវ និងជាគ្រូបង្វឹកនៅវិទ្យាស្ថានអេស៊ីលីដា ផ្នែកពាណិជ្ជកម្ម។

លោក សឹង ភន បានបម្រើការងារនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី អស់រយៈពេលជាង ២២ឆ្នាំ តាំងពីឆ្នាំ១៩៩៨មកម្ល៉េះ ជាមួយនឹងតួនាទីដឹកនាំជាច្រើន ដែលក្នុងនោះរួមមាន ជានាយករង ជាប្រធានសវនកម្មផ្ទៃក្នុង ជាអ្នកដឹកនាំក្រុម ជាប្រធាននាយកឥណទាន ជានាយករង នៃផ្នែកសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងឥណទាន ជានាយករងផ្នែកឥណទាន និងជាទីប្រឹក្សាឥណទាននៅក្នុងប្រទេសកម្ពុជា មីយ៉ាម៉ា និងឡាវ។

លោក សឹង ភន បានទទួលបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ផ្នែកគណនេយ្យ និងសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម។



## លោក CHARANIA SHAHID

**អភិបាល**

លោក CHARANIA Shahid ជានាយកគ្រប់គ្រងទីផ្សារកំពុងអភិវឌ្ឍ ប្រចាំនៅក្រុមហ៊ុន Equifax Inc. ដែលលោកបានមកកាន់មុខតំណែងនេះនៅក្នុងខែកក្កដា ឆ្នាំ២០០៨ ហើយលោកបានខិតខំប្រឹងប្រែងដឹកនាំក្រុមហ៊ុនក្នុងការពង្រីកទីផ្សារដែលកំពុងអភិវឌ្ឍ នៅក្នុងប្រទេសរុស្ស៊ី ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ទួរគី និងទីផ្សារស្រដៀងគ្នាផ្សេងទៀត។ លោកទទួលខុសត្រូវក្នុងការបង្កើតទិសដៅយុទ្ធសាស្ត្រ ក្នុងការពង្រីកវិស័យទាំងនេះ និងទទួលខុសត្រូវក្នុងការកសាង និងរក្សាបាននូវទំនាក់ទំនងសមស្របនៅក្នុងទីផ្សារទាំងនេះ ហើយនិងការប្រតិបត្តិការអាជីវកម្មរបស់ Equifax នៅតាមបណ្តាប្រទេសទាំងនេះផងដែរ ។

លោក CHARANIA Shahid មានបទពិសោធន៍ជាង២៥ឆ្នាំក្នុងប្រតិបត្តិការ និងការអភិវឌ្ឍអាជីវកម្ម ដែលលោកបានកាន់មុខតំណែងជាច្រើននៅក្នុងក្រុមហ៊ុនផ្សេងៗនៅបណ្តាប្រទេសមួយចំនួន និងការត្រួតពិនិត្យការងារជាច្រើនផ្សេងគ្នា។ លោក ក៏កាន់តំណែងជាក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនជាច្រើន ដូចជា Fidelity E-fund Equifax Russia និង Fortune BPO ។ មុនពេលចូលរួមជាមួយ Equifax លោកបានកាន់តំណែងជាថ្នាក់ដឹកនាំជា National Information Services នៃក្រុមហ៊ុន Fidelity។ លោក CHARANIA Shahid ទទួលបានបរិញ្ញាបត្រវិទ្យាសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យា ។



## លោក LIM WILLIAM

### អភិបាល

លោក LIM William គឺជានាយកប្រតិបត្តិនៃការិយាល័យឥណទានសិង្ហបុរី (CBS) ។ លោកគឺជាផ្នែកមួយនៃក្រុមការងារដែលបានបង្កើត CBS ហើយបានគ្រប់គ្រង ចាប់តាំងពីការចាប់ផ្តើមប្រតិបត្តិការនៅឆ្នាំ ២០០២ ។
លោកបានដឹកនាំគំនិតផ្តួចផ្តើមបង្កើតការិយាល័យឥណទាននៅក្នុងតំបន់អាស៊ាន ហើយទទួលបានអាជ្ញាប័ណ្ណ និងការអនុម័តដោយជោគជ័យដើម្បីប្រតិបត្តិការការិយាល័យឥណទាននៅក្នុងប្រទេសសិង្ហបុរី ម៉ាឡេស៊ី កម្ពុជា មីយ៉ាន់ម៉ា និងឥណ្ឌូនេស៊ី ។
លោក ក៏មានតួនាទីជាក្រុមប្រឹក្សាភិបាលរបស់ការិយាល័យឥណទានសិង្ហបុរី ក្រុមហ៊ុន Dun & Bradstreet Singapore ក្រុមហ៊ុន Dun & Bradstreet Malaysia ក្រុមហ៊ុន Infocredit Holdings ការិយាល័យឥណទានកម្ពុជា និងការិយាល័យឥណទានមីយ៉ាន់ម៉ា។
លោក LIM William ក៏បម្រើការងារជាក្រុមប្រឹក្សាភិបាលផ្តល់យោបល់នៃសមាគមផែនការហិរញ្ញវត្ថុនៃប្រទេសសិង្ហបូរីផងដែរ ។ តាមរយៈការហ្វឹកហ្វឺនជាមេធាវីម្នាក់ លោកធ្លាប់បានបម្រើការងារជាមួយសេវាកម្មច្បាប់សិង្ហបុរីក្នុងតួនាទីជាអនុប្រធានការិយាល័យរដ្ឋបាលចៅក្រម និងជាចៅក្រមថ្នាក់តំបន់ មុនពេលលោកចាកចេញទៅបម្រើការងារឯកជន។ ក្នុងតួនាទីរាជការលោកបានអនុវត្តតាមនីតិវិធីច្បាប់សាជីវកម្ម ច្បាប់នៃទ្រព្យសម្បត្តិ និងច្បាប់ព្រហ្មទណ្ឌ។ លោកបានចាកចេញពីការងារអនុវត្តច្បាប់ ដើម្បីចូលរួមជាមួយក្រុមហ៊ុនឯកជនក្នុងឆ្នាំ ១៩៩៩ ។



## ឯកឧត្តម សុខ ស៊ីផាន់ណា

### អភិបាលឯករាជ្យ

ឯកឧត្តម សុក ស៊ីផាន់ណា ជាមេធាវី និងជានាយកនៅក្រុមហ៊ុន SokSiphana & Associates ដែលជាក្រុមហ៊ុនប្រឹក្សាយោបល់មានជំនាញខាងផ្នែកពាណិជ្ជកម្មអន្តរជាតិ និងច្បាប់សាជីវកម្មនៅរាជធានីភ្នំពេញ ។
ឯកឧត្តម សុក ស៊ីផាន់ណា មានបទពិសោធន៍ និងការយល់ដឹងជាច្រើនទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធច្បាប់នៅកម្ពុជាបរិយាកាសអាជីវកម្ម និងចំណេះដឹងនៃការវិវត្តច្បាប់ពាណិជ្ជកម្មនិងវិនិយោគនៅកម្ពុជា។ ការងារជាច្រើនរបស់ឯកឧត្តមក្នុងបទពិសោធន៍ជាអតីតរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម(អនុរដ្ឋមន្ត្រី)របស់រដ្ឋាភិបាលកម្ពុជា ដែលឯកឧត្តម បានធ្វើការយ៉ាងទូលំទូលាយលើបញ្ហាទាក់ទងនឹងក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្ម និងវិនិយោគការជំរុញពាណិជ្ជកម្ម គោលនយោបាយពាណិជ្ជកម្ម ការអភិវឌ្ឍពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មសេដ្ឋកិច្ច ដែលបទពិសោធន៍ទាំងនេះបានផ្តល់ឲ្យឯកឧត្តមនូវទស្សនៈរួមលើតម្រូវការម៉ាក្រូ និងមីក្រូហិរញ្ញវត្ថុរបស់ពាណិជ្ជកម្ម និងវិនិយោគិនបរទេស ។ សម្រាប់ការងារការបង្កើតគោលនយោបាយ និងបញ្ជ្រាបគោលនយោបាយ ឯកឧត្តម បានទទួលខុសត្រូវក្នុងការដឹកនាំក្រុមការងារភ្នាក់ងារចម្រុះ ដើម្បីរៀបចំផែនការសកម្មភាពផ្សេងៗ (រួមមានរបៀបវារៈនីតិបញ្ញត្តិ និងនីតិបញ្ញត្តិថ្នាក់ជាតិ) និងបានចរចាដោយជោគជ័យនូវការចូលជាសមាជិកភាពរបស់ប្រទេសកម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ឯកឧត្តម ក៏បានចូលរួមក្នុងការផ្តួចផ្តើមបង្កើតនៃវិធីសាស្រ្តផ្នែកពាណិជ្ជកម្ម Sector Wide Approach (SWAp) មុនដំបូងសម្រាប់ប្រទេសកម្ពុជា។
ឯកឧត្តម សុក ស៊ីផាន់ណា ទទួលបានសញ្ញាបត្របណ្ឌិតពី Widener University នៃសាលាច្បាប់ School of Law in Delaware សហរដ្ឋអាមេរិក និងសញ្ញាបត្របណ្ឌិតផ្នែកទស្សនវិជ្ជាពី Bond University នៃសាលាច្បាប់ School of Law in Queensland ប្រទេសអូស្ត្រាលី ។

# គណៈកម្មាធិការនៃ ក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា មាន៤ផ្នែកសំខាន់ៗ ដែលទទួលបន្ទុក ក្នុងការចង្អុលបង្ហាញធ្វើជាតំណាង និងផ្តល់ដំបូន្មានដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រុមហ៊ុន ដើម្បីសម្រេចអោយបាននូវគោលដៅអាជីវកម្ម និងផលប្រយោជន៍រួមរបស់ក្រុមហ៊ុនព្រមទាំងបង្កើតនូវគុណតម្លៃសម្រាប់ភាគទុនិកទាំងអស់។

## គណៈកម្មាធិការទាំងនេះរួមមាន៖

- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
- គណៈកម្មាធិការសវនកម្ម
- គណៈកម្មាធិការផ្តល់កម្រៃតបស្នង
- គណៈកម្មាធិការអភិវឌ្ឍន៍ផលិតផល

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានសមាជិកចំនួន ៣រូប ដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យធនាគារ និងប្រតិបត្តិការការិយាល័យឥណទាន។ គណៈកម្មាធិការនេះ គាំទ្រដល់ក្រុមប្រឹក្សាភិបាលរៀបចំក្របខ័ណ្ឌវាយតម្លៃ និងសម្រេចចិត្តលើការគ្រប់គ្រងផ្ទៃក្នុង និងវចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ។ គណៈកម្មាធិការនេះ រៀបចំកិច្ចប្រជុំរបស់ខ្លួនក្នុងរយៈពេល ៣ខែម្តង ក្រោមការដឹកនាំដោយប្រធានគណៈកម្មាធិការ។ បន្ថែមលើការគ្រប់គ្រង និងការវាយតម្លៃហានិភ័យ គណៈកម្មាធិការនេះ តែងយកចិត្តទុកដាក់ដកស្រង់ចំណុចល្អ និងសំខាន់ៗនៃការអនុវត្តពីខាងក្រៅស្ថាប័ន ដើម្បីជាបំណិនជួយបង្កើនប្រតិបត្តិការរបស់ការិយាល័យឥណទានឲ្យកាន់តែរលូន និងប្រសើរឡើង។ ជាងនេះទៅទៀតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ក៏ធ្វើការត្រួតពិនិត្យកម្រិតប្រឈមសំខាន់ៗក្នុងយុទ្ធសាស្ត្រអាជីវកម្មដែលបានស្នើឡើង។ គណៈកម្មាធិការនេះ ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើកម្រិតហានិភ័យ ដែលក្រុមហ៊ុនអាចទ្រាំទ្រសមស្របតាមបរិបទឧស្សាហកម្មម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងនៅពេលអនាគត ហើយធ្វើការស្នើឲ្យមានការវិវឌ្ឍនានានៅក្នុងក្រុមហ៊ុនជាបន្តបន្ទាប់។

សមាសភាពគណៈកម្មការគ្រប់គ្រងហានិភ័យមានដូចខាងក្រោម៖

**លោក LIM William**
*មានតួនាទីជា ប្រធាន*

**លោកជំទាវ ជា សិរី**
*មានតួនាទីជា សមាជិក*

**លោក RAYMOND Sia Say Guan**
*មានតួនាទីជា សមាជិក*

## គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម មានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យ តាមដានលើសុចរិតភាពគណនេយ្យ និងដំណើរការរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាម។ យន្តការត្រួតពិនិត្យនេះ ក៏មានតួនាទីផ្តល់នូវទំនុកចិត្តទៅលើសុចរិតភាពនៃការអនុវត្តរបស់ក្រុមហ៊ុន។ គណៈកម្មាធិការសវនកម្ម អនុវត្តតួនាទីរបស់ខ្លួនដោយត្រួតពិនិត្យទៅលើសវនកម្មផ្ទៃក្នុង និងឈរលើវិសាលភាពរួមមួយនៃសនវកម្មផ្ទៃក្នុង និងខាងក្រៅដើម្បីជៀសវៀងការងារសមប្បមាណ។

គណៈកម្មាធិការនេះមានសមាជិកចំនួន ៤រូប និងដឹកនាំដោយប្រធានប្រកបដោយកិត្តិនាម ដែលមានតួនាទីសំខាន់ក្នុងការផ្តល់ភាពជាអ្នកដឹកនាំដល់គណៈកម្មាធិការសវនកម្ម និងអនុវត្តអំណាចជំនួសឲ្យគណៈកម្មាធិការ។

សមាសភាពគណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

**លោក គា បូរាណ**
*មានតួនាទីជា ប្រធាន*

**លោក RAYMOND Sia Say Guan**
*មានតួនាទីជា សមាជិក*

**លោក សឹង ភន**
*មានតួនាទីជា សមាជិក*

**លោក CHARANIA Shahid**
*មានតួនាទីជា សមាជិក*

## គណៈកម្មាធិការផ្តល់កម្រៃតបស្នង

គណៈកម្មាធិការផ្តល់កម្រៃតបស្នង ត្រូវបានបង្កើតឡើងដើម្បីធានាដល់ការរៀបចំផ្តល់តម្លៃតបស្នង ដែលជាកត្តាចាំបាច់ក្នុងការគាំទ្រដល់ផែនការ និងយុទ្ធសាស្រ្តអាជីវកម្មក្រុមហ៊ុន និងជួយដល់ការជ្រើសរើសបុគ្គលិក ការលើកទឹកចិត្ត និងការរក្សាបុគ្គលិកផងដែរ។ ក្នុងន័យនេះគណៈកម្មាធិការមានការទទួលខុសត្រូវក្នុងការកំណត់នូវការផ្តល់កម្រៃតបស្នងមិនត្រឹមតែតាមរយៈការស្នើសុំឲ្យផ្តល់រង្វាន់លើកទឹកចិត្តសមរម្យប៉ុណ្ណោះទេ ថែមទាំងអត្ថប្រយោជន៍នៃសុខុមាលភាពផ្សេងទៀត ដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន និងលក្ខខណ្ឌការងារដែលមានភាពប្រកួតប្រជែងដល់បុគ្គលិក។

គណៈកម្មាធិការផ្តល់កម្រៃតបស្នង មានសមាជិក ៣រូប ហើយគណៈកម្មាធិការនេះដឹកនាំដោយអភិបាលឯករាជ្យដែលមានបទពិសោធន៍ជាច្រើនក្នុងវិស័យពាក់ព័ន្ធនានា។

សមាសភាពគណៈកម្មាធិការផ្តល់កម្រៃតបស្នងមានដូចខាងក្រោម៖

**ឯកឧត្តម សុក ស៊ីផាន់ណា**
*មានតួនាទីជា ប្រធាន*

**លោកជំទាវ ជា សិរី**
*មានតួនាទីជា សមាជិក*

**លោក LIM William**
*មានតួនាទីជា សមាជិក*

## គណៈកម្មាធិការអភិវឌ្ឍន៍ផលិតផល

ការអភិវឌ្ឍន៍ផលិតផល ជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងយុទ្ធសាស្រ្តរបស់ក្រុមហ៊ុន ដើម្បីធានាបាននូវការបង្កើតគុណតម្លៃរយៈពេលវែង ដើម្បីជាប្រយោជន៍សំរាប់ភាគទុនិកអតិថិជន និយោជិត និងភាគីដែលពាក់ព័ន្ធ។ ដូច្នេះ គណៈកម្មាធិការអភិវឌ្ឍផលិតផល មានគោលបំណងក្នុងការផ្តល់នូវយុទ្ធសាស្រ្តគោលដៅ ការប្រមើលមើលពីចង្កោមផលិតផលរបស់ក្រុមហ៊ុន និងការអភិវឌ្ឍផលិតផលថ្មីៗដែលរួមបញ្ចូលទាំងការតាមដាននូវការអភិវឌ្ឍផលិតផលទៅស្របតាមទិសដៅ យុទ្ធសាស្រ្តរបស់ក្រុមហ៊ុនផងដែរ។ ជាមួយគ្នានេះគណៈកម្មាធិការនេះទទួលខុសត្រូវជួយប្រែក្លាយស៊ីប៊ីស៊ីអោយទៅជាអាជីវកម្មប្រកួតប្រជែង និងបង្កើនប្រាក់ចំណេញជាងមុន។

គណៈកម្មាធិការផលិតផល មានសមាជិក ៤រូប ហើយគណៈកម្មាធិការនេះដឹកនាំដោយអភិបាលឯករាជ្យដែលមានបទពិសោធន៍ច្រើនឆ្នាំ។

សមាសភាពគណៈកម្មាធិការផលិតផលមានដូចខាងក្រោម៖

**លោកជំទាវ ជា សិរី**
*មានតួនាទីជា ប្រធាន*

**លោក គា បូរាណ**
*មានតួនាទីជា ប្រធាន*

**លោក សឹង ភន**
*មានតួនាទីជា សមាជិក*

**លោក CHARANIA Shahid**
*មានតួនាទីជា សមាជិក*

# គណៈគ្រប់គ្រងក្រុមហ៊ុន





## លោក អឿ សុធារ័ត្ន

### ប្រធាននាយកប្រតិបត្តិ

លោក អឿ សុធារ័ត្ន គឺជាអ្នកដឹកនាំវិភាគធុរកិច្ច ដែលមានបទពិសោធន៍ជាង ១៥ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ ស្រាវជ្រាវ និងអភិវឌ្ឍន៍។ បច្ចុប្បន្នលោកជា ប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី។ មុននឹងក្លាយជាប្រធាននាយកប្រតិបត្តិក្នុងឆ្នាំ២០១៧ លោកធ្លាប់ធ្វើជានាយកអភិវឌ្ឍន៍ធុរកិច្ច រយៈពេលបួនឆ្នាំ។

លោកបានដឹកនាំក្រុមហ៊ុនដោយធ្វើកំណែទម្រង់លើប្រព័ន្ធឌីជីថល និងការវិភាគទិន្នន័យ រហូតអាចដាក់អោយដំណើរការបាននូវ ខេ ស្ករ ជំនាន់ទី២ កម្មវិធីទូរស័ព្ទដៃ សំរាប់ត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុដំបូងគេបង្អស់នៅកម្ពុជា និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាដ៏រឹងមាំ ដើម្បីបំរើទៅដល់គ្រឹះស្ថានហិរញ្ញវត្ថុជាង ១៦៧ស្ថាប័នទូទាំងប្រទេស។

ក្នុងអំឡុងឆ្នាំ២០០៩ ដល់២០១៣ លោកបានបម្រើការជាប្រធានផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផល ក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឈានមុខគេមួយក្នុងប្រទេសកម្ពុជា។ ក្នុងអំឡុងពេលនោះដែរ លោកបានបង្កើតនូវក្រុមស្រាវជ្រាវ និងអភិវឌ្ឍន៍មួយប្រកបដោយគុណវុឌ្ឍិ និងបានពង្រីកទីផ្សារ តាមរយៈការបង្កើតសាខាថ្មីជាង ៥០នៅទូទាំងប្រទេស។ លោកក៏បានសម្រេចនូវសមិទ្ធិផលដ៏សំខាន់ៗជាច្រើនផ្សេងទៀតជាមួយនឹងវិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិ (IWMI) និងអង្គការឃែរអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលដែលលោកបានបម្រើការងារនៅទីនោះ។

លោក អឿ សុធារ័ត្ន បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ផ្នែកសេដ្ឋកិច្ចកសិកម្ម និងទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យន័រតុន។ លោកក៏ជាគ្រូបង្គោលផ្នែកមីក្រូហិរញ្ញវត្ថុដែលមានការទទួលស្គាល់ពីមជ្ឈមណ្ឌលអភិវឌ្ឍន៍សិក្សាតូក្យូ និងវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) របស់ប្រទេសជប៉ុន។



## លោក អ៊ាន់ ពលី

### នាយកព័ត៌មានវិទ្យា

នាយកដ្ឋានព័ត៌មានវិទ្យា គឺជានាយកដ្ឋានស្នូលរបស់ក្រុមហ៊ុន ដោយសារតែបច្ចេកវិទ្យាក្នុងវិស័យនេះ មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នាយកដ្ឋាននេះ ត្រូវបានដឹកនាំដោយលោក អ៊ាន់ ពលី ជាអ្នកជំនាញមួយរូបដែលទទួលបានសញ្ញាបត្រជាច្រើន និងមានបទពិសោធន៍យ៉ាងទូលំទូលាយជាង១៤ឆ្នាំនៅក្នុងវិស័យធនាគារ។លោកមានបទពិសោធន៍រៀបចំយុទ្ធសាស្ត្រផ្នែកបច្ចេកវិទ្យា និងបានចូលរួមដោះស្រាយគម្រោងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈស្មុគស្មាញនៅក្នុងវិស័យធនាគារក្នុងប្រទេសកម្ពុជា។ លោក ធ្លាប់បានបំរើការងារនៅក្នុងស្ថាប័នធំៗ និងទទួលបន្ទុកក្នុងការងារសំខាន់ៗជាច្រើនផងដែរ។
លោក អ៊ាន់ ពលី ទទួលបន្ទុកជាអ្នកដឹកនាំក្នុងការរៀបចំគម្រោងយុទ្ធសាស្ត្រ និងដាក់ឲ្យដំណើរការ នូវគម្រោងជាច្រើន នៅក្នុងនាយកដ្ឋានព័ត៌មានវិទ្យា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីរាជបណ្ឌិត្យសភា។ លោក ក៏បានទទួលសញ្ញាបត្រជាច្រើនពីសកលវិទ្យាល័យល្បីៗនៅសហរដ្ឋអាមេរិច ដូចជាMIT សាកលវិទ្យាល័យ Harvard និងBerkeley School of Information លើបច្ចេកវិទ្យា Blockchainបច្ចេកវិទ្យាហេរញ្ញវិត្ថុអនាគត និងវិទ្យាសាស្ត្រទិន្ន័យសំរាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ ជាអ្នកជំនាញ ផ្នែកគ្រប់គ្រង វិស្វករ DevOps និងស្ថាបត្យករ លើ Cloud Amazon Web Services (AWS) និងជាអ្នកជំនាញ ផ្នែកគ្រប់គ្រង និងវិស្វករ DevOps លើ Cloud Microsoft Azure។



## លោក ខុម ច័ន្ទតារា

### នាយករងប្រតិបត្តិការ

នាយកដ្ឋានប្រតិបត្តិការ ជានាយកដ្ឋានដ៏សំខាន់មួយ ដែលទទួលខុសត្រូវចំពោះសមាជិកទាំងអស់របស់ក្រុមហ៊ុន។ នាយកដ្ឋាននេះ ដឹកនាំដោយលោកខុម ច័ន្ទតារា ដែលមានបទពិសោធន៍ការងារជាង ១២ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

លោកខុម ច័ន្ទតារា បានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន ស៊ីប៊ីស៊ី ជានាយករងប្រតិបត្តិការ នៅក្នុងខែមករា ឆ្នាំ ២០១៩។ មុននឹងចូលបម្រើការនៅក្នុងក្រុមហ៊ុនលោកធ្លាប់ជាប្រធានផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ នាយករងនាយកដ្ឋានផែនការ និងយុទ្ធសាស្ត្រ និងជានាយករងនាយកដ្ឋានប្រតិបត្តិការ ទទួលខុសត្រូវលើការស្រាវជាវទីផ្សារ និងអភិវឌ្ឍផលិតផល ការបែងចែកបណ្តាញសាខា ការគាំទ្រប្រតិបត្តិការរបស់សាខាការគ្រប់គ្រងឥណទានការបណ្តុះបណ្តាលបុគ្គលិក និងការធ្វើទីផ្សារ ទាំងក្នុងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

លោក ខុម ច័ន្ទតារា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ និងអនុបណ្ឌិត ផ្នែកគ្រប់គ្រងទូទៅ ពីសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។



## អ្នកស្រី ស៊ីសុវត្ថិ រស្មី

### នាយិកាអភិវឌ្ឍន៍អាជីវកម្ម

នាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម ជានាយកដ្ឋាននាំមកឲ្យក្រុមហ៊ុននូវតម្លៃដ៏សំខាន់ៗ តាមរយៈការលើកស្ទួយការលក់ផលិតផលនានា ដើម្បីបម្រើទៅដល់ទីផ្សារឲ្យបានល្អជាទីបំផុត។ នាយកដ្ឋាននេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកស្រី ស៊ីសុវត្ថិ រស្មី ដែលបានចូលរួមជាមួយក្រុមហ៊ុនកាលពីខែមករា ឆ្នាំ២០១៨ កន្លងទៅ ក្នុងតួនាទីជានាយិការផ្នែកអភិវឌ្ឍន៍អាជីវកម្ម ទទួលបន្ទុកក្នុងការពង្រីក និងបង្កើនប្រាក់ចំណូល នៃសេវាកម្មតម្លៃបន្ថែម។ លោកស្រី ដឹកនាំ និងអភិវឌ្ឍក្រុមការងារទំនាក់ទំនង ដែលជាក្រុមបម្រើការងារយ៉ាងសកម្មជាមួយអតិថិជន ក្នុងគោលបំណងធ្វើការស្វែងយល់ និងផ្តល់ប្រឹក្សាសេវាកម្ម តាមសេចក្តីត្រូវការរបស់ពួកគេ។
មុនចូលបម្រើការងារនៅ ស៊ីប៊ីស៊ី លោកស្រី ស៊ីសុវត្ថិ រស្មី ធ្លាប់បានបម្រើការងារជាមួយធនាគារ ANZ Royal។ លោកស្រី បានបម្រើការងារក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាង ១១ឆ្នាំ ក្នុងតួនាទី និងនាយកដ្ឋានផ្សេងៗ រួមមាន នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ក្នុងការិយាល័យកណ្តាល ជាប្រធានផ្នែកទំនាក់ទំនងអតិជនសម្រាប់ឥណទាន និងសាជីកម្មនៅនាយកដ្ឋានសេវាកម្មធនាគារពាណិជ្ជកម្ម ចូលបម្រើក្នុងនាយកដ្ឋានសេវាកម្មធនាគារសម្រាប់បុគ្គល ទទួលខុសត្រូវសម្របសម្រួលឥណទានជាមួយការិយាល័យវិភាគហានិភ័យឥណទាន និងជាប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម និងផលិតផល និងធ្លាប់បានចូលបម្រើក្នុងនាយកដ្ឋានការិយាល័យនាយកប្រតិបត្តិ ក្នុងតួនាទីជាប្រធានផ្នែកប្រតិបត្តិអាជីវកម្ម។ លោកស្រី បានចាប់ផ្តើមការងារដំបូងជាមួយក្រុមហ៊ុន Nestle (Cambodia) Co. Ltd. នៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុ និងគ្រប់គ្រង។
លោកស្រី ស៊ីសុវត្ថិ រស្មី ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុនិងគណនេយ្យពីវិទ្យាស្ថានជាតិគ្រប់គ្រងកម្ពុជា សញ្ញាបត្របរិញ្ញាបត្រភាសាអង់គ្លេស ពីសាកលវិទ្យាល័យ ន័រតុន ក្រោយមកលោកស្រីក៏បានបន្តការសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យ Charles Sturt University។



## លោក PRADHAN PRASHANTA

### នាយកស្រាវជ្រាវ និងអភិវឌ្ឍន៍

លោក PRASHANTA Pradhan បានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន ស៊ីប៊ីស៊ី ក្នុងឆ្នាំ ២០២០ ក្នុងតួនាទី ជានាយកផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍។ នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍ មានទំនួលខុសត្រូវលើការបង្កើតផលិតផលថ្មីសំរាប់ក្រុមហ៊ុនចាត់ចែងគោលនយោបាយ និងផ្តួចផ្តើមការស្រាវជ្រាវ ក៏ដូចជាដឹកនាំផ្នែកទីផ្សារ និងទំនាក់ទំនង។

មុននឹងចូលបម្រើការងារក្នុងក្រុមហ៊ុន លោក ធ្លាប់ជាទីប្រឹក្សាអភិវឌ្ឍន៍វិស័យឯកជន នៅ UNDP ប្រចាំកម្ពុជា ដែលលោក បានផ្តល់ជាគំនិតដល់ដៃគូសហការរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍប្រព័ន្ធវិភាគទិន្នន័យ និងសមត្ថភាព ក្នុងការគ្រប់គ្រងក្នុងវិស័យឯកជនប្រកបដោយប្រសិទ្ធិភាព។ លោក PRASHANTA Pradhan បានមករស់នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៦ ជាទីប្រឹក្សាគោលនយោបាយពាណិជ្ជកម្ម អោយ GIZ (សហគ្រាសសម្ព័ន្ធអាល្លឺម៉ង់ សំរាប់ការអភិវឌ្ឍន៍អន្តរជាតិ) ដែលលោក បានជួយគាំទ្ររាជរដ្ឋាភិបាល និងអាជីវកម្មនៅប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ក្នុងការធ្វើសមាហរណកម្មទីផ្សារអាស៊ានតែមួយ។ លោក ក៏ធ្លាប់ធ្វើការជាទីប្រឹក្សា ក្នុងក្រុមការងារផ្នែកវិស័យសាធារណៈប្រចាំអាស៊ីប៉ាស៊ីហ្វិក នៅក្រុមហ៊ុនប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រ Frost & Sullivan ក្នុងប្រទេសម៉ាឡេស៊ី។

លោក PRASHANTA Pradhan ទទួលសញ្ញាបត្រអនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ ពីសាលាគោលនយោបាយសាធារណៈ លី ក្វាន់ យូ នៃសាកលវិទ្យាល័យជាតិសង្ហបុរី។ លោក ក៏បានទទួលសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ពីប្រទេសឥណ្ឌា និងសញ្ញាបត្របរិញ្ញាបត្រ ផ្នែកប្រព័ន្ធពត៌មានវិទ្យា ពីប្រទេសនេប៉ាល់ ផងដែរ។



## អ្នកស្រី ប៉ុន បញ្ញាវត្តី

### នាយិកាវិភាគទិន្នន័យ

នាយកដ្ឋានវិភាគទិន្នន័យ គឺជានាយកដ្ឋានតែមួយគត់ ដែលទទួលបន្ទុកគ្រប់គ្រងទៅលើដំណោះស្រាយបែបវិភាគ និងការគ្រប់គ្រងទិន្នន័យនៅក្នុងក្រុមហ៊ុន។ នាយកដ្ឋាននេះដឹកនាំដោយអ្នកស្រី ប៉ុន បញ្ញាវត្តី ដែលមានបទពិសោធន៍ជាង ១១ឆ្នាំ ក្នុងតួនាទីគ្រប់គ្រងទិន្នន័យជាច្រើន ដែលរួមមាន ការងារវិភាគ និងផ្ទៀងផ្ទាត់ទិន្នន័យ ការងារត្រួតពិនិត្យគុណភាព និងរៀបចំរបាយការណ៍។

អ្នកស្រី ប៉ុន បញ្ញាវត្តី ចាប់ផ្តើមធ្វើការជាមួយក្រុមហ៊ុន ក្នុងតួនាទីជាអ្នកវិភាគទិន្នន័យ កាលពីខែធ្នូ ឆ្នាំ២០១៣។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំជាមួយក្រុមហ៊ុន អ្នកស្រីបានចូលរួមក្នុងគម្រោងសំខាន់ៗជាច្រើន ដូចជាការអភិវឌ្ឍរបាយការណ៍វិភាគទិន្នន័យអនឡាញ និងបង្កើតសេវាត្រួតពិនិត្យឥណទានផ្សេងៗ ដែលរបាយការណ៍ទាំងនេះអនុញ្ញាតឱ្យសមាជិកពិនិត្យឡើងវិញនូវផលប័ត្រឥណទានរបស់អតិថិជនខ្លួន ហើយក៏ផ្តល់នូវរបាយការណ៍ដែលមានបច្ចុប្បន្នភាព។ មុនពេលចូលបម្រើការងារនៅក្នុងក្រុមហ៊ុន ស៊ីប៊ីស៊ី អ្នកស្រីបានធ្វើការឲ្យអង្គការ Mines Advisory Group ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ក្នុងតួនាទីជាអ្នកសម្របសម្រួល និងទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងទិន្នន័យ តាមរយៈការបញ្ចូលទិន្នន័យ ផ្ទៀងផ្ទាត់ ពិនិត្យគុណភាព និងធ្វើរបាយការណ៍។ ម្យ៉ាងទៀត អ្នកស្រី ក៏ចូលរួមក្នុងការអភិវឌ្ឍផែនទីផ្លូវផ្គង ដោយប្រើឧបករណ៍វិភាគស្ថិតិ GIS និង SPSS ដើម្បីធ្វើការវិភាគ និងការស្ទង់មតិមូលដ្ឋាន ។

អ្នកស្រី ប៉ុន បញ្ញាវត្តី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្ម ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។



## លោក ផៃ សុផល

### នាយករងសេវាអតិថិជន

នាយកដ្ឋានសេវាអតិថិជនមាន ៣ផ្នែកសំខាន់ ដូចជាផ្នែកធនធានមនុស្ស ផ្នែករដ្ឋបាល និងលទ្ធកម្ម និងផ្នែកសេវាអតិថិជន ដែលមានគោលបំណងបម្រើសេវាកម្មអតិថិជនទាំងក្នុង និងក្រៅ ទាក់ទងនឹងការឆែករបាយការណ៍ឥណទានតាមរយៈទូរស័ព្ទដៃ ស្ថាប័នដៃគូសហការណ៍ និងការិយាល័យស៊ីប៊ីស៊ី។ នាយកដ្ឋាននេះ ត្រូវបានដឹកនាំដោយលោក ផៃ សុផល ដែលមានបទពិសោធន៍ជាង ១១ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ បច្ចេកវិទ្យាហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាលនានា។ លោក បានចូលបម្រើការងារនៅក្នុង ស៊ីប៊ីស៊ី ជាប្រធានផ្នែកអភិវឌ្ឍន៍ផលិតផល ក្នុងឆ្នាំ ២០១៦ ហើយបន្ទាប់មកលោកបានផ្លាស់ប្តូរជាប្រធានផ្នែកទីផ្សារ ដែលទទួលខុសត្រូវលើការធ្វើអោយស្គាល់ម៉ាកសញ្ញារបស់ក្រុមហ៊ុន ការទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធទាំងអស់ និងការផ្សព្វផ្សាយដល់សាធារណជន។ លោក បានត្រូវតែងតាំងជានាយករងផ្នែកសេវាអតិថិជន នៅក្នុងឆ្នាំ ២០២០។

មុនពេលចូលធ្វើការនៅក្រុមហ៊ុន លោក ផៃ សុផល ធ្លាប់បានធ្វើការទៅលើវិស័យផ្សេងៗជាច្រើន ដូចជាផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ ផ្នែកអភិវឌ្ឍន៍ផលិតផល ផ្នែកទីផ្សារផលិតផល ផ្នែកទីផ្សារ និងផ្នែកធនធានមនុស្ស។ លោក បានចាប់ផ្តើមការងារដំបូងជាបុគ្គលិក នៅក្នុងអង្គការ ភី អេស អាយ មានតួនាទីជាភ្នាក់ងារអប់រំ មុននឹងចូលធ្វើការនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏ល្បីមួយ នៅកម្ពុជា។ បន្ទាប់មក លោក បានទៅបម្រើការងារនៅធនាគារឯកទេស វីង ជាបុគ្គលិក ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផល ហើយត្រូវបានតម្លើងតំឡែងជាមន្ត្រីជាន់ខ្ពស់ ផ្នែកផលិតផលទីផ្សារ ដែលទទួលបន្ទុកលើការរៀបចំយុទ្ធសាស្ត្រផលិតផលចូលទីផ្សារ។

លោក បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកសហគ្រិនភាព និងគ្រប់គ្រងគម្រោង ដែលជាកម្មវិធីសហការរវាងសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាមួយនឹងសាកលវិទ្យាល័យ Lumière Lyon 2 របស់ប្រទេសបារាំង។ លោកក៏បានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាសពីសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកភាសាអង់គ្លេសពីវិទ្យាស្ថានភាសាបរទេស (IFL)។



## លោក ច្រឹក សុធា

### នាយកគ្រប់គ្រងហានិភ័យ និងអនុលោមតាម

នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងអនុលោមតាម ដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងក្រុមហ៊ុន ដោយត្រូវទទួលខុសត្រូវក្នុងការតាមដានរាល់កត្តាដែលត្រូវអនុលោមតាមទាំងអស់ ក៏ដូចជាការតាមដានរាល់ហានិភ័យ ដែលអាចកើតឡើងជាយថាហេតុ ដោយផ្ទាល់ ឬដោយប្រយោលមកលើក្រុមហ៊ុន។ ដោយផ្អែកទៅលើបទពិសោធន៍ជាច្រើននៅក្នុងក្រុមហ៊ុន លោក ច្រឹក សុធាជាមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ជាង ១១ឆ្នាំ នៅក្នុងវិស័យធនាគារ និងការគ្រប់គ្រងទិន្នន័យ បានផ្លាស់ប្តូរពីនាយកដ្ឋានប្រតិបត្តិការ មកកាន់នាយកដ្ឋានហានិភ័យ និងអនុលោមតាម។ នៅអំឡុងពេលដែលលោកគាត់កាន់តួនាទីផ្នែកប្រតិបត្តិការ លោកបានទទួលខុសត្រូវក្នុងការសម្របសម្រួលដំណើរការ និងលំហូរប្រតិបត្តិការជាមួយសមាជិកនាពេលនោះ ដែលជាពេលដែលក្រុមហ៊ុនទើបបានបង្កើតឡើងថ្មី។ លោកបានចាប់ផ្តើមជាមួយក្រុមហ៊ុនក្នុងតួនាទីជាមន្ត្រីអភិវឌ្ឍន៍អាជីវកម្ម ទទួលខុសត្រូវក្នុងការទាក់ទង និងពន្យល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនាពេលនោះក្នុងការចូលជាសមាជិករបស់ក្រុមហ៊ុន ក៏ដូចជាជួយសម្រួលដល់ដំណើរការចុះបញ្ជី និងបង្កើតក្រុមហ៊ុន ដូច្នេះហើយលោកជាបុគ្គលសំខាន់មួយរូប ដែលបានចូលរួមបង្កើតក្រុមហ៊ុន ស៊ីប៊ីស៊ី នេះឡើង។

មុនពេលចូលរួមជាមួយក្រុមហ៊ុន ស៊ីប៊ីស៊ី លោក ច្រឹក សុធា បានបម្រើការងារនៅសមាគមធនាគារនៅកម្ពុជាអស់រយៈពេល ៦ឆ្នាំ។ សកម្មភាព និងការចូលរួមរបស់លោកក្នុងសមាគមធនាគារនៅកម្ពុជា បាននាំមកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងសមាជិកទាំងអស់។ ក្នុងអំឡុងពេលបម្រើការងាររបស់លោកនៅក្នុងសមាគមនេះ លោក ច្រឹក សុធា បានបម្រើការនៅក្នុងគណៈកម្មាធិការ ៥ ផ្សេងគ្នាដែលរួមមានគណៈកម្មធិការទូទាត់ គណៈកម្មធិការSWIFT គណៈកម្មធិការ PSWG (ក្រុមការងារវិស័យឯកជន) គណៈកម្មធិការរៀបចំកម្មវិធី និងជាពិសេស គណៈកម្មធិការសម្រាប់បង្កើតការិយាល័យឥណទាន។

លោក ច្រឹក សុធា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យន័រតុន និងសញ្ញាបត្រអនុបណ្ឌិត ផ្នែកគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យ បៀលប្រាយ។



## កញ្ញា លាង សូលីដា

### ប្រធានសវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺជានាយកដ្ឋានមួយដែលមិនអាចរំលងបានដែលមានតួនាទីយ៉ាងសំខាន់មួយក្នុងការបំពេញនូវភាពខ្វះខាត ឬចន្លោះប្រហោងណាមួយដែលអាចកើតឡើងជាយថាហេតុ។ កញ្ញា លាង សូលីដា ដែលបានចូលរួមជាមួយក្រុមហ៊ុន កាលពីខែតុលា ឆ្នាំ២០១៧ ជាអ្នកដឹកនាំនាយកដ្ឋានដ៏សំខាន់មួយនេះ។ មុននឹងចាប់ផ្តើមជាមួយក្រុមហ៊ុន កញ្ញា បានបម្រើការងារ ជាប្រធានសវនកម្ម នៅក្រុមហ៊ុន ខូវេណិនថ៍ អិលធីឌី ដែលជាក្រុមហ៊ុនគណនេយ្យក្នុងតំបន់ទទួលអាជ្ញាប័ណ្ណជាមួយវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (KICPAA) នៅរាជធានីភ្នំពេញ ហើយកញ្ញា ក៏ធ្លាប់បានបម្រើការនៅក្នុងក្រុមហ៊ុនសវនកម្ម អឺនស្ទ័ អ៊ែនយ៉ាំង (ខេមបូឌា) និងនៅធនាគារកាណាឌីយ៉ា ក.អ.។

កញ្ញា លាង សូលីដា ទទួលបានវិញ្ញាបនបត្រជាន់ខ្ពស់ ជំនាញគណនេយ្យ និងពាណិជ្ជកម្ម ពី The Association of Chartered Certified Accountants ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស។ កញ្ញា ក៏បានទទួលបរិញ្ញាបត្រ ផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិញ្ញាបនបត្រ ផ្នែក ច្បាប់ពាណិជ្ជកម្មកម្ពុជា និងពន្ធដារកម្ពុជាពី CamEd Business School រួមជាមួយនឹងការបញ្ចប់វគ្គហ្វឹកហ្វឺនអំពីសវនកម្មផ្ទៃក្នុង ពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ផងដែរ។



## អ្នកស្រី គា សៅវ៉ារិន

### ប្រធានហិរញ្ញវត្ថុ

នាយកដ្ឋានហិរញ្ញវត្ថុ គឺជានាយកដ្ឋានសំខាន់មួយចំណោមនាយកដ្ឋានផ្សេងទៀតក្នុងការផ្តល់ព័ត៌មានហិរញ្ញវត្ថុទៅអ្នកប្រើប្រាស់ទាំងខាងក្នុង និងខាងក្រៅឲ្យដើម្បីយកវាទៅប្រើប្រាស់តាមមុខងារអាជីវកម្មឲ្យមានប្រសិទ្ធភាពគាំទ្រលើការធ្វើផែនការអាជីវកម្មនិងការសំរេចចិត្តផ្សេងៗនៅក្នុងក្រុមហ៊ុន។

អ្នកស្រី គា សៅវ៉ារិន គឺជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុដែលទទួលបានសញ្ញាប័ត្រជាច្រើន និងបទពិសោធន៍យ៉ាងទូលំទូលាយប្រមាណ ៩ឆ្នាំលើវិស័យមីក្រូហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ លោកស្រី គឺអ្នកគ្រប់គ្រងក្នុងការកំណត់ទិសដៅ និងដំណើការនៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុន។

លោកស្រីទទួល បានសញ្ញាបត្របរិញ្ញាប័ត្រផ្នែកគណនេយ្យពី វិទ្យាស្ថានវ៉ាន់ដា និងសញ្ញាប័ត្របញ្ជាក់ជាភ្នាក់ងារសេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារ។ លើសពីនេះទៅទៀត លោកស្រី ធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងទៅនឹងការការគ្រប់គ្រងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។

# ៣. ផលិតផល និងសេវាកម្ម

# ពីអាជីវកម្មទៅអតិថិជន (B2C)

**1**

របាយការណ៍ឥណទាន

**2**

ខេស្ករ

**3**

ការត្រួតពិនិត្យព័ត៌មានឥណទានផ្ទាល់ខ្លួន

**4**

កម្មវិធីទូរស័ព្ទស៊ីប៊ីស៊ី

ស៊ីប៊ីស៊ី អនុញ្ញាតឲ្យអតិថិជនទូទៅអាចប្រើប្រាស់សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ។ សេវាកម្មនេះ អាចឲ្យអតិថិជនម្នាក់ៗ គ្រប់គ្រងនូវព័ត៌មានឥណទាន និងប្រើប្រាស់យ៉ាងពេញលេញនូវអត្ថប្រយោជន៍របស់សេវាកម្មនេះ ដូចជាការពិនិត្យរបាយការណ៍ឥណទាន ពិន្ទុឥណទាន និងការពិនិត្យមើលសកម្មភាពជាប្រចាំលើគណនីប្រាក់កម្ចីរបស់ខ្លួនផងដែរ។ សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ អាចជួយអតិថិជនដូចជា៖

- បង្កើតទម្លាប់ល្អក្នុងការប្រើប្រាស់ឥណទាន
- បង្កើនភាពត្រឹមត្រូវ និងសុពលភាពរបស់ទិន្នន័យ
- បង្កើតចំណេះដឹងខាងផ្នែកហិរញ្ញវត្ថុ និងបរិយាប័ន្ន
- បង្កើនភាពងាយស្រួលដល់អតិថិជន

## របាយការណ៍ឥណទាន

របាយការណ៍ឥណទានផ្ទាល់ខ្លួន គឺជាកំណត់ត្រានៃព័ត៌មានលម្អិតនៃប្រវត្តិសងត្រឡប់របស់អ្នកខ្ចីឥណទាន។ ព័ត៌មាននោះ រួមមានប្រភេទគណនី ក៏ដូចជាព័ត៌មានផ្សេងៗដែលត្រូវបានរាយការណ៍ទៅ ស៊ីប៊ីស៊ី ដោយស្ថាប័នផ្តល់កម្ចី។ ស៊ីប៊ីស៊ី ប្រមូលព័ត៌មានឥណទានរបស់បុគ្គលម្នាក់ៗ រួចបង្កើតរបាយកាណ៍ឥណទានដោយផ្អែកលើព័ត៌មានទាំងនោះ។ ម្ចាស់ឥណទាន អាចប្រើប្រាស់របាយការណ៍ទាំងនេះ ព្រមទាំងព័ត៌មានលម្អិតផ្សេងទៀតដើម្បីកំណត់លទ្ធភាពសងឥណទានរបស់អ្នកស្នើសុំកម្ចី ដែលនេះជាផ្នែកមួយ ជួយដល់ដំណើរការសម្រេចចិត្តរបស់ពួកគេក្នុងការផ្តល់ឥណទាននៅក្នុងកម្រិតណា។ ប្រវត្តិសងឥណទានត្រឡប់មកវិញល្អនឹងធ្វើឲ្យការទទួលឥណទានថ្មីកាន់តែមានភាពឆាប់រហ័ស និងកាន់តែងាយស្រួល។ ដូចគ្នានេះដែរ ម្ចាស់ក្រុមហ៊ុន ក៏អាចសុំ របាយការណ៍ឥណទានរបស់អ្នក ដើម្បីសម្រេចថាតើត្រូវផ្តល់ការងារដល់អ្នក ឬទេ។ ក្រុមហ៊ុនធានារ៉ាប់រង ក៏អាចប្រើប្រាស់ព័ត៌មានទាំងនេះ ក្នុងការផ្តល់ការធានារ៉ាបរងផងដែរ។

វាពិតជាមានសារៈសំខាន់ណាស់ក្នុងការផែកនូវរបាយការណ៍ឥណទានឲ្យបានទៀងទាត់ដើម្បីកំណត់ថាព័ត៌មានដែលនៅក្នុងនោះជាព័ត៌មានដែលពិតប្រាកដ និងត្រឹមត្រូវ។ នេះជាទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗក្នុងការឆែករបាយការណ៍ឥណទានរបស់ពួកគេ និងស្នើសុំកែតម្រូវនៅពេលមានព័ត៌មានដែលមិនត្រឹមត្រូវ។ អតិថិជនអាចស្នើសុំឆែករបាយការណ៍ឥណទានបានតាមរយៈវិធីទាំងបួនដូចជា កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ី មកការិយាល័យស៊ីប៊ីស៊ី ដោយផ្ទាល់ សាខាទាំងអស់នៃធនាគារអេស៊ីលីដា ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ព្រមទាំងកម្មវិធីស្មាតហ្វូនរបស់គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ។



Personal Credit Report

## ខេ ស្ករ

ខេស្ករគឺជាការវាយតម្លៃលើកម្រិតហានិភ័យនិងព្យាករណ៍ទៅលើលទ្ធភាពនៃការអាក់ខានសងបំណុលរបស់អ្នកស្នើសុំឥណទាន។ វាជាពិន្ទុមួយ ដែលបង្កើតដោយការសង្ខេបរាល់ព័ត៌មានទាំងអស់នៃព័ត៌មានឥណទាន ផ្អែកតាមការវិភាគបែបស្ថិតិ។ ពិន្ទុខេស្ករ មានចាប់ពី ១០០ (ទាបបំផុត) ទៅដល់ ១៧០០ (ខ្ពស់បំផុត)។

ពិន្ទុខេស្កររបស់បុគ្គលម្នាក់ៗ ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកផ្តល់ឥណទានក្នុងការសម្រេចចិត្ត ផ្តល់ប្រាក់កម្ចី ឬប័ណ្ណឥណទានដល់អតិថិជន និងជួយក្នុងការកំណត់អត្រាការប្រាក់ផងដែរ ។ ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់ ខេស្ករ ជំនាន់ថ្មី នៅក្នុងឆ្នាំ២០២០ ហើយឥឡូវនេះ វាក៏មាននៅក្នុងកម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ីផងដែរ។

### កត្តាសំខាន់ៗដែលជះឥទ្ធិពលទៅកាន់ខេស្ករ

**រយៈពេលនៃប្រវត្តិឥណទាន៖**
អ្នកខ្ចីដែលរមានប្រវត្តិឥណទានល្អរយៈពេលយូរ ភាគច្រើនទទួលបានពិន្ទុឥណទានខ្ពស់។

**ព័ត៌មានមិនល្អ៖**
រាល់ពេលមានការកត់ត្រាអំពីឥណទានខូចពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នផ្សេងទៀត វាផ្តល់ផលអវិជ្ជមានទៅដល់ពិន្ទុរបស់បុគ្គលម្នាក់ៗ។

**ការផ្តល់ឥណទាន៖**
សំដៅលើចំនួននិងប្រភេទផលិតផលឥណទានដែលមាន និងការបើកចំនួនគណនីញឹកញាប់ដែលអាចបង្ហាញពីស្ថានភាពបំណុលវណ្ឌកហើយវានឹងប៉ះពាល់ដល់ពិន្ទុឥណទានរបស់ពួកគេ។

**ការដាក់ពាក្យស្នើសុំឥណទាន៖**
អ្នកដែលមានកម្រិតហានិភ័យខ្ពស់ភាគច្រើនតែងតែដាក់ពាក្យស្នើសុំឥណទានច្រើន។ ពិន្ទុខេស្ករ នឹងវាស់វែងលើនិន្នាការនៃការដាក់ពាក្យស្នើសុំឥណទាន ក្នុងរយៈពេលជាក់លាក់ណាមួយ។

**ឥរិយាបទក្នុងការបង់សងត្រឡប់៖**
បុគ្គលដែលមានការបង់សងគ្រប់ជាប់លាប់ និងទាន់ពេលវេលា អាចមានពិន្ទុខ្ពស់ជាងអ្នកបង់សងយឺតយ៉ាវ។



## ការត្រួតពិនិត្យព័ត៌មានឥណទានផ្ទាល់ខ្លួន

ការត្រួតពិនិត្យព័ត៌មានឥណទាន អាចជួយកាត់បន្ថយការក្លែងបន្លំ និងព័ត៌មានមិនត្រឹមត្រូវ។ ស៊ីប៊ីស៊ី បានបញ្ចូល "ការត្រួតពិនិត្យរបស់ខ្ញុំ" (My Monitoring) ទៅក្នុងកម្មវិធីទូរស័ព្ទដៃ ដើម្បីការពារអតិថិជនពីបញ្ហាដែលអាចកើតមានឡើង។ អតិថិជន ក៏អាចទទួលបានការរំលឹកពីការតាមដានឥណទានរបស់ខ្លួន ផ្អែកទៅលើលក្ខខណ្ឌផ្សេងៗ ដែលបានជ្រើសរើស។ អតិថិជននឹងទទួលបាននូវការជូនដំណឹងភ្លាមៗ ប្រសិនបើចូលលក្ខខណ្ឌណាមួយ ឬច្រើននៃលក្ខខណ្ឌខាងក្រោមដូចគ្នា៖

**ខកខានបង់ត្រូឡប់សង៖**
ទទួលបានការជូនដំណឹងភ្លាមៗនៅពេលដែលមានការខកខានបង់សងត្រូឡប់ទៅស្ថាប័នហិរញ្ញវត្ថុ។

**ការបង់សងត្រូឡប់ទាន់ពេលវេលា៖**
ទទួលបានការជូនដំណឹងភ្លាមៗនៅពេលដែលមានការបង់សងត្រូឡប់ទាន់ពេលវេលាទៅស្ថាប័នហិរញ្ញវត្ថុ។

**ការបិទគណនី៖**
ទទួលបានការជូនដំណឹងភ្លាមៗនៅពេលបង់សងផ្តាច់ និងបិទគណនីជាមួយស្ថាប័នហិរញ្ញវត្ថុ។

**ការស្នើសុំឥណទានថ្មី៖**
ទទួលបានការជូនដំណឹងភ្លាមៗនៅពេលដែលមានការស្នើសុំកម្ចីថ្មីពីស្ថាប័នហិរញ្ញវត្ថុ។

**ការបង្កើតគណនីថ្មី៖**
ទទួលបានការជូនដំណឹងភ្លាមៗនៅពេលបង្កើតគណនីថ្មីជាមួយស្ថាប័នហិរញ្ញវត្ថុ។




## កម្មវិធីទូរស័ព្ទស៊ីប៊ីស៊ី (ជាផ្លែតហ្វមមួយ ដែលមានផលិតផលទាំងអស់)

អតិថិជនអាចប្រើប្រាស់កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ី ក្នុងការពិនិត្យមើលនូវរបាយការណ៍ឥណទានរបស់ពួកគេយ៉ាងងាយស្រួល ដោយពុំចាំបាច់មកកាន់ការិយាល័យរបស់ស៊ីប៊ីស៊ីដោយផ្ទាល់ ឬតាមរយៈសាខាភ្នាក់ងារណាមួយឡើយ។ នៅពេលដែលអតិថិជនបើកដំណើរការគណនីទូរស័ព្ទដៃហើយ អតិថិជនអាចពិនិត្យមើលនូវរបាយការណ៍ឥណទាន ដើម្បីតាមដានប្រវត្តិឥណទានរបស់ខ្លួនជាមួយនឹងគ្រឹះស្ថានហរិញ្ញវត្ថុទាំងអស់ និងពិនិត្យមើលឡើងវិញនូវលទ្ធភាពដែលអាចទទួលបានឥណទានរបស់ពួកគេបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

ជាងនេះទៅទៀត អតិថិជនអាចត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ពួកគេប្រសើរជាងមុនតាមរយៈ "ការត្រួតពិនិត្យរបស់ខ្ញុំ" ដើម្បីរក្សានូវទម្លាប់ល្អនៃការប្រើប្រាស់ឥណទាន ត្រៀមខ្លួនក្នុងការចាប់យកឱកាសហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យឥណទាន បង្កើតលទ្ធភាពក្នុងការចរចារ និងអាចធ្វើការស្នើសុំកែតម្រូវនូវព័ត៌មានដែលមិនត្រឹមត្រូវតាមរយៈសេវាកម្មដោះស្រាយវិវាទតាមប្រព័ន្ធអនឡាញរបស់យើង។ អតិថិជន ក៏អាចទទួលបានពិន្ទុខេស្កូររបស់ពួកគេ តាមកម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ីផងដែរ។









**Standard**
**៩,៩០០៛/ខែ**

**គិតថ្លៃជាប្រចាំឆ្នាំ**

- ✓ ៤ របាយការណ៍ឥណទាន (ទទួលបានរាល់៣ខែម្តង)
- ✓ ៦ ខេ ស្កូរ (ទទួលបានរាល់៣ខែម្តង)
- ✓ ជូនដំណឹង
  - ជូនដំណឹងនៅពេលមានការខកខានបង់ប្រាក់
  - ជូនដំណឹងការស្នើរសុំកម្ចីថ្មី

**Premium**
**១៩,៩០០៛/ខែ**

**គិតថ្លៃជាប្រចាំឆ្នាំ**

- ✓ ៦ របាយការណ៍ឥណទាន (ទទួលបានរាល់២ខែម្តង)
- ✓ ១២ ខេ ស្កូរ (ទទួលបានរាល់២ខែម្តង)
- ✓ ជូនដំណឹង
  - ជូនដំណឹងនៅពេលមានការខកខានបង់ប្រាក់
  - ជូនដំណឹងចំនួនគណនីឥណទានដែលបានបិទ
  - ជូនដំណឹងនៃការបើកគណនីថ្មី
  - ជូនដំណឹងទឹកប្រាក់បង់សងទៀងទាត់

**Basic**
**៣,៩០០៛/ខែ**

**គិតថ្លៃជាប្រចាំឆ្នាំ**

- ✓ ១ របាយការណ៍ឥណទាន
- ✓ ២ ខេ ស្កូរ
- ✓ ជូនដំណឹង
  - ជូនដំណឹងនៅពេលមានការខកខានបង់ប្រាក់

ក្រៅពីនេះ កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ី ផ្តល់នូវចំណេះដឹងលើផ្នែកហិរញ្ញវត្ថុ ភាពងាយស្រួលក្នុងការទទួលបានព័ត៌មានឥណទាន ព័ត៌មានថ្មីៗដែលទាក់ទងនឹងទីផ្សារឥណទាន និងនិន្នាការផ្សេងៗក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយនូវព័ត៌មានលំអៀងរវាងអ្នកផ្តល់ឥណទាន និងអ្នកខ្ចី ដើម្បីអោយដំណើរការទីផ្សារឥណទានកាន់តែប្រសើរឡើង។ កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ីបានចូលរួមចំណែកបង្កើននូវទំលាប់ប្រើប្រាស់ឥណទានដោយការទទួលខុសត្រូវដែលជាកត្តាជំរុញអោយមានស្ថិរភាព និងនិរន្តរភាពនៃវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

# ពីអាជីវកម្មទៅអាជីវកម្ម (B2B)

**1**
របាយការណ៍ឥណទានក្រុមហ៊ុន

**2**
របាយការណ៍ឥណទានអតិថិជន

**3**
ខេ ស្ករ

**4**
ការអភិវឌ្ឍពិន្ទុវាយតម្លៃឥណទាន

**5**
សេវាវិភាគទិន្នន័យ

**6**
សេវាតាមដានឥណទាន

**7**
សេវាត្រួតពិនិត្យឥណទាន

**8**
ដំណោះស្រាយទិន្នន័យតាមតម្រូវការ

## របាយការណ៍ឥណទានក្រុមហ៊ុន

របាយការណ៍ឥណទានក្រុមហ៊ុន គឺជាការកត់ត្រារាល់ព័ត៌មានប្រវត្តិឥណទានរបស់នីតិបុគ្គលដែលមាននៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ សេវាកម្មនេះបានដាក់ឲ្យដំណើរការតាំងពីខែកញ្ញា ឆ្នាំ២០១៩ មកម្ល៉េះ។ នៅពេលដែលអាជីវកម្មកាន់តែរីកលូតលាស់ អាជីវកម្មទាំងនោះតែងត្រូវការទុនបន្ថែម។ ប្រភពទុនមួយក្នុងចំណោមប្រភពទុនផ្សេងៗ គឺបានមកពីការស្នើសុំឥណទានក្រុមហ៊ុនពីធនាគារ។ ក្នុងដំណើរការស្នើសុំឥណទាន ធនាគារនឹងត្រូវពិនិត្យមើលនូវរបាយការណ៍ឥណទានក្រុមហ៊ុន ដែលបានស្នើសុំតាមរយៈប្រព័ន្ធស៊ីប៊ីស៊ី ក្នុងគោលបំណងដឹងអំពីលទ្ធភាពសងត្រឡប់ និងប្រវត្តិឥណទានរបស់ក្រុមហ៊ុនផងដែរ។ ចំនួនអ្នកផ្តល់កម្ចី និងអ្នកវិនិយោគ ដែលបានសំរេចផ្តល់ឥណទាន ដោយផ្អែកលើរបាយការណ៍ឥណទានក្រុមហ៊ុន មានការកើនឡើងកាន់តែច្រើនឡើងៗ។

វាពិតជាមានសារៈសំខាន់ណាស់ ក្នុងការពិនិត្យរបាយការណ៍ឥណទានក្រុមហ៊ុនឲ្យបានទៀងទាត់ ដោយសារតែក្រុមហ៊ុន អាចដឹងអំពីស្ថានភាព និងលទ្ធភាពក្នុងការសងត្រឡប់ នៅពេលដាក់ពាក្យស្នើសុំឥណទាន អោយត្រួតពិនិត្យលើប្រវត្តិ និងព័ត៌មានឥណទានថាត្រឹមត្រូវដែរឬទេ ព្រមទាំងអាចស្នើសុំកែប្រែព័ត៌មានដែលមិនត្រឹមត្រូវជាមួយនឹងស៊ីប៊ីស៊ីផងដែរ។ ក្រុមហ៊ុនអាចមកទទួលយករបាយការណ៍ឥណទានក្រុមហ៊ុន នៅការិយាល័យ ស៊ីប៊ីស៊ីដោយផ្ទាល់បាន ។

### របាយការណ៍ឥណទានក្រុមហ៊ុន ផ្តល់នូវព័ត៌មានសំខាន់ៗទាំងប្រាំដូចជា ៖

**1** ប្រវត្តិក្រុមហ៊ុន

**2** សង្ខេបនូវរបាយការណ៍ឥណទាន

**3** ការត្រួតពិនិត្យរបាយការណ៍ឥណទានពីមុន

**4** ព័ត៌មានលម្អិតពីគណនី

**5** ព័ត៌មានភាគទុនិក

## របាយការណ៍ឥណទានអតិថិជន

របាយការណ៍ឥណទានអតិថិជនគឺជាការកត់ត្រានូវប្រវត្តិឥណទាននៃការបង់សងត្រឡប់របស់អតិថិជនម្នាក់ៗ ដែលព័ត៌មានទាំងនេះបានមកពីគ្រឹះស្ថានធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។ គ្រឹះស្ថានផ្តល់ឥណទានត្រូវទាញយករបាយការណ៍នេះ ដែលជាផ្នែកមួយនៃដំណើរការវាយតម្លៃទៅពាក្យស្នើសុំឥណទាន។ គ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាសមាជិករបស់ ស៊ីប៊ីស៊ី មានសិទ្ធិទទួលបានរបាយការណ៍ឥណទានរបស់អតិថិជនដោយផ្ទាល់តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ស៊ីប៊ីស៊ី ប៉ុន្តែក៏ទាមទារឲ្យមានការយល់ព្រមពីអតិថិជនជាមុនផងដែរ។

របាយការណ៍ឥណទានអតិថិជន បានដើរតួនាទីយ៉ាងសំខាន់ដើម្បីកាត់បន្ថយនូវព័ត៌មានលំអៀងរវាងអ្នកផ្តល់ឥណទាន និងអ្នកខ្ចីដែលជាការរួមចំណែកក្នុងការគ្រប់គ្រងកម្រិតហានិភ័យឥណទាន និងបង្កើនប្រសិទ្ធភាពក្នុងការសម្រេចចិត្តផ្តល់ឥណទាន។

**បង្កើនការវាយតម្លៃហានិភ័យ**

បង្កើនសុក្រឹតភាពនៃការវាយតម្លៃហានិភ័យឥណទាន ដែលអាចកាត់បន្ថយបំណុលវណ្ឌក

**បង្កើនឧត្តមភាពប្រកួតប្រជែង និងប្រសិទ្ធភាព**

អាចទទួលបានឥណទានច្រើនក្នុងតម្លៃទាបជាងមុនដោយសារការកាត់បន្ថយចំណាយប្រតិបត្តិ

**ការផ្តល់កម្ចីប្រកបដោយទំនួលខុសត្រូវ**

ផ្តល់កម្ចីអោយតែអ្នកដែលអាចមានលទ្ធភាពក្នុងការបង់សងត្រឡប់មកវិញជៀងវាងនូវបំណុលវណ្ឌក

## ព័ត៌មានដែលបង្ហាញក្នុងរបាយការណ៍ឥណទានអតិថិជន

**ព័ត៌មានប្រជាសាស្ត្រ៖**

ព័ត៌មានទូទៅដែលបង្ហាញពីអត្តសញ្ញាណដូចជាឈ្មោះ ភេទ ស្ថានភាព ថ្ងៃខែកំណើត ទីកន្លែងកំណើត និងសញ្ជាតិ។

**ចំនួនរបាយការណ៍ឥណទានដែលបានត្រួតពិនិត្យពីមុន៖**

មានតារាងបង្ហាញពីចំនួនអ្នកផ្តល់កម្ចីដែលបានត្រួតពិនិត្យរបាយការណ៍ឥណទានរបស់អ្នក។

**ព័ត៌មានពីកន្លែងការងារ ៖**

បង្ហាញពីព័ត៌មានលម្អិតនៃការងារដូចជាកន្លែងធ្វើការ តួនាទី និងរយៈពេលបម្រើការងារក៏ដូចជាប្រាក់ខែផងដែរ។

**ប្រវត្តិសង្ខេប៖**

សង្ខេបពីការរបាយការណ៍ឥណទាន និងគណនី រួមមានប្រាក់ដើមឥណទានជាសរុប ចំនួនគណនីបឋម និងគណនីធានា។

**ព័ត៌មានលម្អិតអំពីគណនី៖**

បង្ហាញពីព័ត៌មានលម្អិតនៃគណនីទាំងអស់រួមមានគណនីសកម្ម និងគណនីបិទដែលមានជាមួយស្ថាប័នដៃគូរបស់ស៊ីប៊ីស៊ី។

## ខេ ស្ករ




K-Score is calculated based on an individual's available credit data and is a number which may change from time to time in tandem with change in their credit file. Key contributing factors:

1 Utilization Pattern
2 Credit Commitment
3 Payment Behavior
4 Adverse Information
5 Enquiry Activity

ខេ ស្ករ (ពិន្ទុខ្មែរ) គឺជាតួលេខ ដែលវាស់ស្ទង់អំពីកម្រិតហានិភ័យឥណទានរបស់បុគ្គលម្នាក់ ក្នុងពេលជាក់លាក់មួយ និងទស្សទាយអំពីលទ្ធភាពនៃការអាក់ខានបង់សងបំណុលត្រឡប់នាពេលអនាគត។ ខេ ស្ករ ត្រូវបានគណនាផ្អែកលើទិន្នន័យរបាយការណ៍ឥណទានដែលមាននៅក្នុងប្រព័ន្ធ ស៊ីប៊ីស៊ី តាមរយៈឥរិយាបទក្នុងការសងបំណុលកន្លងមក និងប្រវត្តិឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់។ ម្ចាស់ឥណទាន អាចប្រើប្រាស់ ខេ ស្ករ ជាមួយនឹងពិន្ទុឥណទានដែលមានក្នុងស្ថាប័នរបស់ខ្លួនដើម្បីវិភាគអំពីកម្រិតហានិភ័យរបស់អតិថជនបានកាន់តែសុក្រឹត្យ។

**ខេ ស្ករ**
ត្រូវបានបង្កើតសម្រាប់ម្ចាស់ឥណទាននូវប្រវិត្តហានិភ័យដោយផ្អែកលើទិន្នន័យស៊ីប៊ីស៊ីក្នុងការវាយតម្លៃពីលទ្ធភាពបង់សងត្រឡប់របស់បុគ្គលម្នាក់ៗ។

**ខេ ស្ករ**
ត្រូវបានបង្កើតឡើងដោយសង្ខេបរាល់ព័ត៌មានឥណទានទៅជាពិន្ទុមួយផ្អែកលើការគណនាបែបស្ថិតិ។

**ខេ ស្ករ**
អាចទស្សទាយលទ្ធភាពនៃការអាក់ខានសងត្រឡប់មកវិញរបស់បុគ្គលម្នាក់ៗ ក្នុងរយៈពេលពី ៦-១២ខែបន្ទាប់ពីទទួលកម្ចី។

# អត្ថប្រយោជន៍នៃខេស្ករ សម្រាប់ម្ចាស់ឥណទាន



CBC Consumer Credit Report *(Member version)*

| | | | |
|---|---|---|---|
| Report Date | 30/01/2019 | Enquiry Type | New Application |
| Enquiry Number | 279945340 | Product Type | Public Housing Loan |
| Number of Applicants | 1 | Account Type | Single |
| Reference Number | BBN-001-20190130-1 | Amount | USD 50,000.00 |

**K-Score**

Risk Grade : AA
K-Score : 1600
Bad Rate : 0.1%
1600

EE DD CC BB AA
100 925 1100 1250 1400 1700

K-Score is calculated based on an individual's available credit data and is a number which may change from time to time in tandem with change in their credit file. Key contributing factors:

1 Length of Credit History 2 Credit Commitment 3 Payment History 4 Adverse Information 5 Enquiry Activity

**Data Provided vs (Primary Data Available)**

| | | |
|---|---|---|
| Applicant Type | Primary | |
| ID Type and Number | National ID 060935446 | (National ID 060935446) |
| ID Expiry Date | 14/07/2026 | (27/11/2026) |
| Khmer Name | | |
| Family Name | [illegible] | [illegible] |
| First Name | [illegible] | [illegible] |
| Second Name | | |
| Third Name | | |
| Unformatted Name | | |
| English Name | | |
| Family Name | San | (Sarn) |
| First Name | Sokuntheary | (Sokuntheari) |
| Second Name | | |
| Third Name | | |
| Unformatted Name | | |
| Date of Birth | 04/06/1986 | (04/06/1986) |
| Place of Birth Country | Cambodia | (Cambodia) |
| Place of Birth Province | Kep | (Kep) |
| Place of Birth District | Damnak Chang'aeur | (Damnak Chang'aeur) |
| Place of Birth Commune | Sangkat Ou Krasar | (Sangkat Ou Krasar) |
| Gender | Female | (Female) |
| Marital Status | Married | (Married) |
| Nationality | Cambodia | (Cambodia) |

**Summary**

| | |
|---|---|
| All Previous Enquiries | 3 |
| Enquiries for Previous 30 Days | 0 |
| Earliest Loan Issued Date | 24/04/2015 |
| Total Accounts | 2 |
| Normal Accounts | 1 |
| Delinquent Accounts | 0 |
| Closed Accounts | 1 |
| Reject Accounts | 0 |
| Write Off Accounts | 1 |
| Total Limits | USD 22,000.00<br>KHR 20,000,000.00 |
| Total Liabilities | USD 18,000.00<br>KHR 2,100,000.00 |
| Total Write Off Amounts | USD 18,000.00 |
| Outstanding Write Off Balance | USD 12,000.00 |
| | |
| Guaranteed Accounts | 0 |
| Normal Accounts | 0 |
| Delinquent Accounts | 0 |
| Closed Accounts | 0 |
| Reject Accounts | 0 |
| Write Off Accounts | 0 |
| Total Guaranteed Limits | 0.00 |
| Total Guaranteed Liabilities | 0.00 |
| Total Guaranteed Write Off Amounts | 0.00 |
| Outstanding Guaranteed Write Off Balance | 0.00 |

**Additional Identification**

| Date Loaded | ID Type | ID Number | Expiry Date |
|---|---|---|---|
| 02/05/2016 | Passport | N09554127 | 10/12/2028 |

**Additional Names**

| Date Loaded | Name |
|---|---|
| 13/03/2015 | Sarn, Sokuntheary |

**Previous Enquiries**

| Date of Enquiry | Enquirer | Enquiry Type | Account Type | Member Reference | Product Type | Amount | Applicant Type | Name |
|---|---|---|---|---|---|---|---|---|
| 25/09/2018 | MICROFINANCE C | New Application | Single | 205_PLN_1234567 | Community Loan | THB 1,000,000.00 | Primary | Sarn, Sokuntheari [illegible] |
| 02/05/2016 | BANK B | New Application | Single | 257_CRC_1234567 | Unsecured Credit Card | USD 2,000.00 | Primary | Sarn, Sokuntheary |
| 13/03/2015 | BANK A | New Application | Joint | 205_PLN_2345678 | Working Capital Loan | KHR 20,000,000.00 | Primary | Sarn, Sokuntheary |

**Account Details**

| | | | |
|---|---|---|---|
| Creditor | Bank AAAAA | Issue Date | 24/04/2015 |
| Product Type | Working Capital Loan | Expiry Date | 24/04/2025 |
| Applicant Type | Primary | | |

## A. ការដាក់ពាក្យស្នើសុំឥណទាន

**ការពិនិត្យពាក្យស្នើសុំ**

- ម្ចាស់ឥណទាន អាចជ្រើសរើសយកតែអ្នកដែលមានពិន្ទុជាក់លាក់ណាមួយ
- ខេ ស្ករ អាចយកប្រើប្រាស់ ដើម្បីការវាយតម្លៃបន្ថែម

**ការវាយតំលៃប្រាក់កម្ចី**

- ម្ចាស់ឥណទាន អាចកំណត់ពិន្ទុជាក់លាក់ណាមួយនៃខេស្ករ ដើម្បីវាយតម្លៃមុនពេលផ្តល់កម្ចី

** ពិន្ទុដែលខ្ពស់ អាចជួយឲ្យដំណើរការពិនិត្យ និងផ្តល់កម្ចីបានលឿន ឬដោយស្វ័យប្រវត្តិ ដោយមិនតំរូវនូវឯកសារភ្ជាប់បន្ថែម ឬការចុះវាយតម្លៃនៅទីតាំងជាក់ស្តែង ។*

## B. ការគ្រប់គ្រងផលិតកម្ម និងផលប័ត្រឥណទាន

**ការកំណត់តម្លៃដោយផ្អែកលើកម្រិតហានិភ័យ**

- ម្ចាស់ឥណទាន អាចប្រើប្រាស់ពិន្ទុ ខេ ស្ករ ជាសូចនាករមួយក្នុងការកំណត់អត្រាការប្រាក់ជាមួយអ្នកខ្ចីដែលមានប្រវត្តិហានិភ័យខុសៗគ្នា។

**ការកំណត់កញ្ចប់ផលិតផលដោយផ្អែកលើកម្រិតហានិភ័យ**

- ម្ចាស់ឥណទាន អាចប្រើប្រាស់ពិន្ទុ ខេ ស្ករ ជាសូចនាករមួយសម្រាប់កំណត់នូវលក្ខខណ្ឌផ្សេងៗនៃផលិតកម្មឥណទាន (ដូចជារយៈពេលខ្ចី ទ្រព្យបញ្ចាំ)។

**ការពិនិត្យឡើងវិញ និងការកំណត់ស្តង់ដាផលប័ត្រឥណទាន**

- ម្ចាស់ឥណទាន អាចស្នើសុំខេស្កររបស់អ្នកខ្ចីដែលមានស្រាប់បាន ក្នុងកម្រិតស្ថាប័ន ឬវិស័យទាំងមូល ដើម្បីត្រួតពិនិត្យមើលពីការគ្រប់គ្រង ឥណទានរបស់ខ្លួន ធៀបនឹងវិស័យទាំងមូល ហើយរៀបចំយុទ្ធសាស្ត្រកែតម្រូវប្រសិនបើចំាបាច់។

## C. ការគ្រប់គ្រងការផ្តល់ឥណទាន

- ម្ចាស់ឥណទានអាចកម្រិតការផ្តល់កម្ចីសំរាប់តែអ្នកដែលមានពិន្ទុខេស្ករខ្ពស់ប៉ុណ្ណោះ។ដូចនេះខេស្ករអាចយកមកប្រើប្រាស់ជាឧបករណ៍ក្នុងការកំណត់ការផ្តល់ឥណទាន។

## ការអភិវឌ្ឍពិន្ទុវាយតម្លៃឥណទាន

ម្ចាស់ឥណទាន អាចបង្កើតពិន្ទុវាយតម្លៃឥណទានរបស់ខ្លួន ដោយប្រើប្រាស់ខេ ស្ករ  ក៏ដូចជាព័ត៌មាននៃប្រវត្តិនៃការបង់សងត្រឡប់មកវិញរបស់អតិថិជន។ ការវាយតម្លៃកម្រិតហានិភ័យនៃការអាក់ខានក្នុងការសងត្រឡប់ នឹងមានភាពកាន់តែសុក្រឹត្យ ប្រសិនបើម្ចាស់ឥណទាន ប្រើប្រាស់ពិន្ទុឥណទានរបស់ស្ថាប័ន គួបផ្សំនឹង ខេ ស្ករ។ ខេ ស្ករ គឺជាពិន្ទុ ដែលបានមកពីការសង្ខេបនូវរាល់ព័ត៌មានឥណទានដែលមានស្រាប់នៅក្នុងទិន្នន័យរបស់ស៊ីប៊ីស៊ី។ពិន្ទុវាយតម្លៃឥណទានសំដៅទៅលើពិន្ទុឥណទានគណនាដោយប្រើប្រាស់ក្បួនខ្នាតគណិតវិទ្យាដែលបានប្រើប្រាស់នូវព័ត៌មានពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុជាក់លាក់មួយ ដើម្បីកំណត់ពិន្ទុនៃអ្នកស្នើសុំឥណទាន ឬអ្នកកំពុងខ្ចី។

## អត្ថប្រយោជន៍នៃការអភិវឌ្ឍពិន្ទុវាយតម្លៃឥណទាន

ការប្រើប្រាស់ការវាយតម្លៃឥណទានជួយឲ្យគ្រឹះស្ថានហិរញ្ញវត្ថុធ្វើការសម្រេចចិត្តបានលឿន និងប្រសើរជាងមុន ជាលទ្ធផលដូចខាងក្រោម៖

### បង្កើនប្រសិទ្ធភាព
- ធ្វើឲ្យការសម្រេចចិត្តផ្នែកឥណទានកាន់តែប្រសើរ ដែលអាចឈានទៅដល់ការសម្រេចចិត្តដោយស្វ័យប្រវត្តិ។
- កាត់បន្ថយដំណើរការទាំងមូល និងធ្វើការសម្រេចចិត្តបានលឿនជាងមុន។

### បង្កើនសង្គតភាព
- មានស្តង់ដា និងបង្កើនតម្លាភាពនៃដំណើរការសម្រេចចិត្តលើឥណទាន។
- កាត់បន្ថយ ឬលុបបំបាត់ដំណើរការក្នុងសម្រេចចិត្តដោយខ្លួនឯង និងសម្រួលដល់ការកែប្រែគោលការណ៍ឥណទាន។

### កែលម្អគុណភាពផលប័ត្រឥណទានទាំងមូល
- ផ្តល់នូវឧបករណ៍គ្រប់គ្រងហានិភ័យឥណទាន ដែលមានភាពត្រឹមត្រូវ និងអាចទុកចិត្តបាន ដើម្បីកំណត់ និងកែលម្អការសម្រេចចិត្តឥណទានឲ្យទាន់ពេលវេលា។
- ជួយឲ្យអាជីវកម្មអនុវត្តយុទ្ធសាស្រ្តចម្រុះ ដើម្បីបង្កើនប្រសិទ្ធភាពអាជីវកម្ម។

### បង្កើនប្រសិទ្ធភាពការវាយតម្លៃ និងសម្រេចចិត្តផ្នែកឥណទាន
- ដើម្បីឆ្លើយតបនឹងការប្រែប្រួលរបស់ទីផ្សារយ៉ាងឆាប់រហ័ស និងការកើនឡើងនូវបទដ្ឋានច្បាប់ជាច្រើន ធនាគារធំៗបានអនុម័តនូវការវាយតម្លៃឥណទាន ដើម្បីធ្វើឱ្យដំណើរការវាយតម្លៃផ្នែកឥណទានរបស់ពួកគេកាន់តែប្រសើរឡើង។

### បង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្រ្តឥណទាន
- ភាពងាយស្រួលក្នុងការប្រើឧបករណ៍វិភាគទិន្នន័យ ជាមួយនឹងតម្លៃសមរម្យ បានធ្វើឱ្យមានការចាប់ផ្តើមប្រើប្រាស់វិធីសាស្រ្តវិភាគទិន្នន័យ ដើម្បីប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យឥណទាន។ សព្វថ្ងៃនេះ ធនាគារកំពុងដណ្តើមគ្នាចូលកៀកអតិថិជន ដើម្បីយកឈ្នះដៃគូប្រកួតអាជីវកម្មរបស់ពួកគេ។ ដូចនេះ ស្ថាប័នត្រូវមានដំណើរការវាយតម្លៃឥណទានដែលមានប្រសិទ្ធភាព រហ័ស និងឆ្លាតវៃ ។

## សេវាវិភាគទិន្នន័យ

សេវាវិភាគទិន្នន័យ គឺជាទម្រង់របាយការណ៍ឆ្លាតវៃមួយ ដែលអនុញ្ញាតឲ្យសមាជិកប្រើប្រាស់សេវានេះ អាចពិនិត្យមើលយ៉ាងច្បាស់ទៅលើប្រតិបត្តិការរបស់ពួកគេ ប្រៀបធៀបទៅនឹងវិស័យទាំងមូល។ សេវាវិភាគទិន្នន័យ មាន៥ទម្រង់ដូចជា៖

**ការគ្រប់គ្រងអតិថិជនថ្មី**

ពង្រឹងគុណភាពអតិថិជនថ្មី ដើម្បីពង្រឹងផលប័ត្រឥណទានរបស់អ្នក

**ការគ្រប់គ្រងគណនីឥណទានយឺតយ៉ាវ**

តាមដានគុណភាពផលប័ត្រឥណទាន ដើម្បីកាត់បន្ថយហានិភ័យ

**ការគ្រប់គ្រងលើតម្រូវការ ឥណទានឡើងវិញ**

កាត់បន្ថយអត្រាបោះបង់ការបន្តប្រើប្រាស់សេវាពីអតិថិជន និងលើកកម្ពស់យុទ្ធសាស្រ្តគាំពារអតិថិជន

**ការគ្រប់គ្រងគណនី ឥណទាន**

ស្វែងយល់ស៊ីជម្រៅលើការគ្រប់គ្រងគុណភាពផលប័ត្រឥណទានទាំងមូលរបស់អ្នក

**ការគ្រប់គ្រងការប្រមូលឥណទាន**

ពង្រីកលទ្ធភាពក្នុងការស្វែងរកមធ្យោបាយថ្មីៗក្នុងការកែលម្អការប្រមូលឥណទាន

### អត្ថប្រយោជន៍៖

- មានភាពងាយស្រួលក្នុងការតាមដាននូវដំណើរគ្រប់គ្រងឥណទានរបស់ស្ថាប័នខ្លួននៅក្នុងរង្វង់ដៃដោយធៀបទៅនឹងវិស័យ និងឧស្សាហកម្មទាំងមូល
- តាមដានព័ត៌មានលម្អិតពីស្ថានភាពល្អតលាស់នៃផលិតផលនីមួយៗប្រៀបធៀបទៅនឹងឧស្សាហកម្ម
- យល់ច្បាស់ពីស្ថាប័នរបស់ខ្លួន ក្នុងការទាក់ទាញអតិថិជនថ្មីៗពីដៃគូប្រកួតប្រជែង
- ទទួលបាននូវទស្សនៈសំខាន់ៗពាក់ព័ន្ធនឹងសមិទ្ធផលលើទីផ្សារនៃផលិតផលដែលមិនទាន់មានរបស់ស្ថាប័ន ដោយមានសារៈសំខាន់ក្នុងយុទ្ធសាស្រ្តអភិវឌ្ឍផលិតផលថ្មី

## សេវាតាមដានឥណទាន

សេវាតាមដានឥណទាន គឺជួយស្ថាប័នតាមដានសកម្មភាពរបស់អតិថិជនដែលមានស្រាប់ឲ្យបានទាន់ពេលវេលា។ សេវាកម្មនេះ មានចំណុចសំខាន់ទាំង១៣ ដូចជា៖

១ ការស្នើសុំរបាយការណ៍ឥណទានរបស់អតិថិជន

២ អតិថិជនទទួលបានកិច្ចសន្យាឥណទានថ្មី

៣ ការផ្លាស់ប្តូរឯកសារអត្តសញ្ញាណសម្គាល់អតិថិជន

៤ បច្ចុប្បន្នភាពនៃគណនីអតិថិជនបានប្តូរពី “ធម្មតា” ទៅ “លុបចោល”

៥ ស្ថានភាពឥណទាន លុបចោល ត្រូវបានផ្លាស់ប្តូរ

៦ ឥណទាន ត្រូវបានប្តូរទៅជា “ការបិទគណនី”

៧ ការបង់ប្រាក់របស់អតិថិជនបានប្តូរពី “ល្អ” ទៅ “មិនល្អ”

៨ ការបង់ប្រាក់របស់អតិថិជនបានប្តូរពី “មិនល្អ” ទៅ “ល្អ”

៩ អតិថិជនមានការបង់ប្រាក់យឺតយ៉ាវ

១០ អតិថិជនបានទូទាត់ទឹកប្រាក់ដែលបានបង់យឺត

១១ អតិថិជនធ្វើបច្ចុប្បន្នភាពអាសយដ្ឋានស្នាក់នៅថ្មី

១២ អតិថិជនមានការផ្លាស់ប្តូរការបង់ប្រាក់យឺតយ៉ាវ

១៣ គណនីអតិថិជនត្រូវបានចាត់ថ្នាក់ថា “បាត់បង់”

### សេវាកម្មថ្មី៖ "ការរៀបចំឥណទានឡើងវិញ"

ចាប់តាំងពីមានការរីករាលដាលជំងឺកូវីដ១៩ គ្រឹះស្ថានហិរញ្ញវត្ថុ បានបង្កើតនូវគោលការណ៍ និងនីតិវិធី អនុញ្ញាតឲ្យមានការរៀបចំឥណទានឡើងវិញដល់អ្នកខ្ចីដែលរងផលប៉ះពាល់ដោយសារការរីករាលដាននេះ។ នេះបានបញ្ជាក់ឲ្យឃើញថាម្ចាស់ឥណទាន ត្រូវតែតាមដានអតិថិជនអោយបានទៀងទាត់។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិក ក្នុងការតាមដានឥណទានរៀបចំឡើងវិញនៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ស៊ីប៊ីស៊ី បានដាក់ឲ្យប្រើប្រាស់សេវាកម្មថ្មីនេះ ក្នុងឆ្នាំ២០២០ ដោយផ្តល់ព័ត៌មាននៅពេលដែលអតិថិជនធ្វើការរៀបចំឥណទានឡើងវិញ។

## អត្ថប្រយោជន៍៖

- តាមដានការអនុវត្តរបស់អតិថិជនចាស់ និងស្ថានភាពឥណទានរបស់ពួកគេ
- អាចគ្រប់គ្រងការអនុវត្តរបស់អតិថិជនបានភ្លាមៗ
- កាត់បន្ថយហានិភ័យដោយការត្រៀមទុកជាមុន
- ចំណាយប្រកបដោយប្រសិទ្ធភាពក្នុងការត្រួតពិនិត្យអតិថិជនរបស់អ្នក

## សេវាត្រួតពិនិត្យឥណទាន

សេវាត្រួតពិនិត្យឥណទាន គឺជាដំណោះស្រាយ offline ដែលអាចឲ្យសមាជិកត្រួតពិនិត្យរបាយការណ៍ឥណទានរបស់អតិថិជនទាំងអស់ ដែលជួយឲ្យស្ថាប័នយល់ដឹងកាន់តែច្បាស់ពីស្ថានភាពឥណទានរបស់អតិថិជន និងប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធិភាព។ គោលដៅចម្បងនៃសេវាកម្មនេះ គឺធ្វើការវិភាគ និងតាមដានកម្រិតហានិភ័យរបស់ផលប័ត្រឥណទាននៅស្ថានភាពជាក់លាក់ណាមួយ។

**ព័ត៌មានលម្អិត**
និងទិន្នន័យដើមនៃព័ត៌មានអតិថិជនរបស់អ្នក

**ព័ត៌មានជាច្រើន**
(ទិដ្ឋភាពសំខាន់ៗជាច្រើន)

**ចន្លោះ**
សម្រាប់ការវិភាគទូលំទូលាយ សម្រាប់គោលបំណងយុទ្ធសាស្រ្ត

## អត្ថប្រយោជន៍៖

- ដឹងអំពីព័ត៌មាន និងប្រវត្តិឥណទានរបស់អតិថិជន
- ជួយសមាជិក ត្រៀមវិធានការទុកជាមុនជាមួយហានិភ័យដែលអាចនឹងកើតមានឡើង
- ជួយឲ្យសមាជិកប្រើប្រាស់ព័ត៌មានក្នុងរបាយការណ៍ ដើម្បីធ្វើការវិភាគស៊ីជម្រៅផ្សេងៗទៀត

## ដំណោះស្រាយទិន្នន័យតាមតម្រូវការ

ដំណោះស្រាយទិន្នន័យតាមតម្រូវការ គឺជាសេវាកម្មវិភាគទិន្នន័យដែលស្របតាមតម្រូវការរបស់អតិថិជន។ យើងស្វែងយល់ពីបញ្ហាប្រឈមរបស់សមាជិក និងគោលដៅជាយុទ្ធសាស្រ្តរបស់ពួកគេ ហើយផ្តល់នូវដំណោះស្រាយ ដែលអាចឆ្លើយតបនឹងបញ្ហាទាំងនោះ។ ស៊ីប៊ីស៊ី ប្រើប្រាស់ទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព ក្នុងការផ្តល់ជូននូវតួលេខដែលត្រឹមត្រូវ និងខ្នាតវាស់វែងស្តង់ដារសម្រាប់ការទាញយកទិន្នន័យជាក់លាក់ណាមួយ។

ខាងក្រោមនេះជាការវិភាគទិន្នន័យតាមតម្រូវការខ្លះៗដែលយើងអាចផ្តល់ជូន

- ការស្រាវជ្រាវទីផ្សារដើម្បីពង្រីកសាខាប្រតិបត្តិការ
- ការវិភាគទីផ្សារឥណទានយានយន្ត
- ការវិភាគទីផ្សារអាជីវកម្មខ្នាតតូច
- ការវិភាគទីផ្សារឥណទានមានទ្រព្យបញ្ចាំ
- ការវិភាគទីផ្សារមីក្រូហិរញ្ញវត្ថុ



# ៤. សកម្មភាពដែលបាន ធ្វើក្នុងឆ្នាំ ២០២០

# ផលិតផលថ្មីដែលត្រូវបានដាក់ឲ្យប្រើប្រាស់

## ខេ ស្ករ ជំនាន់ទី២

ខេ ស្ករ ជំនាន់ទី២ ត្រូវបានបង្កើតឡើងនូវខែវិច្ឆិកា ឆ្នាំ២០២០ សម្រាប់បំពេញនូវតម្រូវការរបស់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាសមាជិក និងអតិថិជនទូទៅ។ ការដាក់ឲ្យប្រើប្រាស់សាកល្បង ត្រូវបានផ្តល់ជូនទៅកាន់សមាជិកស៊ីប៊ីស៊ីទាំងអស់ ដើម្បីឲ្យពួកគាត់ទទួលបានបទពិសោធន៍ថ្មីនៃ ខេ ស្ករ ជំនាន់ថ្មី។ ខេ ស្ករ ជំនាន់ថ្មីនេះ មិនត្រឹមតែជាពិន្ទុ ដែលទទួលបានពីគ្រប់គ្រឹះស្ថានហិរញ្ញវត្ថុប៉ុណ្ណោះទេ ក៏ប៉ុន្តែវាបានបញ្ចូលនូវព័ត៌មានទីផ្សារថ្មីៗ ជាមួយនឹងព័ត៌មានវិជ្ជមាន ដែលជាការបន្ថែមលើ ខេស្ករ ជំនាន់មុន។




K-Score is calculated based on an individual's available credit data and is a number which may change from time to time in tandem with change in their credit file. Key contributing factors:

1. Utilization Pattern
2. Credit Commitment
3. Payment Behavior
4. Adverse Information
5. Enquiry Activity

## កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ី

បេសកកម្មរបស់កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ីគឺដើម្បីបម្រើអតិថិជនតាមប្រព័ន្ធឌីជីថល។ស៊ីប៊ីស៊ី បានដាក់ឲ្យដំណើរការនូវកម្មវិធីទូរស័ព្ទដៃនៅខែធ្នូ ឆ្នាំ២០២០ ជួយឲ្យអ្នកប្រើប្រាស់ អាចឆែកមើលនូវពិន្ទុឥណទាន ត្រួតពិនិត្យមើលរបាយការណ៍ឥណទាន ព្រមទាំងទទួលបានការរំលឹកក្នុងការតាមដានឥណទានជាប្រចាំ។ នេះគឺជាផ្លែតហ្វមទីមួយក្នុងប្រព័ន្ធឌីជីថលដែលបានលើកស្ទួយនូវសុខភាពហិរញ្ញវត្ថុ ការតាមដានឥណទាន និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។







ជាមួយគ្នានេះដែរ កម្មវិធីទូរស័ព្ទដៃស៊ីប៊ីស៊ីបានបំពេញនូវចន្លោះខ្វះខាត នៅពេលដែលប្រទេសកំពុងមានការលូតលាស់ខាងវិស័យឥណទាន និងវិស័យហិរញ្ញវត្ថុ។ បន្ទាប់ពីចុះឈ្មោះជាមួយនឹងកម្មវិធីទូរស័ព្ទស៊ីប៊ីស៊ី ដែលមានទាំងប្រព័ន្ធ iOS និង Android រួចហើយនោះ អ្នកអាចឆែកពិន្ទុឥណទានត្រួតពិនិត្យរបាយការណ៍ឥណទាន ព្រមទាំងទទួលបានការរំលឹកក្នុងការតាមដានឥណទានជាប្រចាំផងដែរ។

## សេវាវិភាគទិន្នន័យ

សេវាវិភាគទិន្នន័យជំនាន់ថ្មី ត្រូវបានដាក់ឲ្យដំណើរការក្នុងខែកញ្ញា ឆ្នាំ២០២០។ សេវាវិភាគទិន្នន័យជំនាន់ថ្មីនេះ មាន៣ទម្រង់បង្កើតជាពិសេស សំរាប់គណៈគ្រប់គ្រងរបស់ស្ថាប័ន អាចតាមដានដំណើរការគ្រប់គ្រងឥណទានរបស់ពួកគេបាន។



### ពីអាជីវកម្មទៅអាជីវកម្ម

- សេវាតាមដានឥណទាន
- របាយការណ៍ឥណទាន ក្រុមហ៊ុន
- របាយការណ៍ឥណទាន អតិថជន
- សេវាតាមដានឥណទាន
- ខេ ស្ករ
- ការអភិវឌ្ឍពិន្ទុវាយតម្លៃឥណទាន
- សេវាត្រួតពិនិត្យឥណទាន
- ដំណោះស្រាយទិន្នន័យ តាមតម្រូវការ

# ពានរង្វាន់ឧត្តមភាពកំរិតពិភពលោក




## ការទទួលស្គាល់នៅលើឆាកអន្តរជាតិនៃរបាយការណ៍ឥណទានអតិថិជន

## GLOBAL
## BUSINESS OUTLOOK

**Excellence in Consumer**
**Credit Reporting - Cambodia**

## 2020
## WINNER

ស៊ីប៊ីស៊ី ទទួលបានពានរង្វាន់ “Excellence in Consumer Credit Reporting” ពី Global Business Outlook (GBO) ដែលជាទស្សនាវដ្តីដ៏ល្បីឈ្មោះមួយនៅក្នុងចក្រភពអង់គ្លេស។ គណៈកម្មាធិការវិនិច្ឆ័យនៃ GBO បានជ្រើសរើស និងវាយតម្លៃស៊ីប៊ីស៊ី សម្រាប់ពានរង្វាន់មួយនេះ ដោយផ្អែកលើសមិទ្ធផលរបស់ស៊ីប៊ីស៊ី ក្នុងការផ្តល់របាយការណ៍ឥណទាននៅកម្ពុជា។ ស៊ីប៊ីស៊ី គឺជាក្រុមហ៊ុនតែមួយគត់ក្នុងប្រទេស ដែលទទួលបានពានរង្វាន់ GBO ក្នុងវិស័យហិរញ្ញវត្ថុនៅឆ្នាំ២០២០។ ពានរង្វាន់របស់ GBO ធ្វើការផ្តល់ជូនដល់ក្រុមហ៊ុននៅជុំវិញពិភពលោកចំពោះការសម្រេចនូវស្នាដៃល្អ ការបង្កើតនូវគុណតម្លៃជាអាជីវកម្មគំរូ និងមានទទួលស្គាល់នៅក្នុងទីផ្សារ។




ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី
របាយការណ៍ប្រចាំឆ្នាំ ២០២០

# ការរក្សាទំនាក់ទំនងជាមួយសមាជិក








## គណៈកម្មាធិការសមាជិកប្រតិបត្តិ

**១៦៨ គ្រឹះស្ថាន**

*ជាសមាជិករបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា)គិតត្រឹម ខែធ្នូ ឆ្នាំ២០២០*

**០៣ នៃអង្គប្រជុំត្រូវបាន រៀបចំឡើង ៣ លើក**

ដោយមានអ្នកចូលរួមចំនួន **៦៨៧** នាក់ មកពី **១៥៤** គ្រឹះស្ថានសមាជិក

គណៈកម្មការសមាជិកប្រតិបត្តិ ផ្តល់ជូននូវទម្រង់នៃកិច្ចប្រជុំពិភាក្សា និងមធ្យោបាយទំនាក់ទំនងប្រកបដោយ ប្រសិទ្ធភាពមួយ ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើព័ត៌មាន និងប្រតិបត្តិការជាប្រចាំរបស់សមាជិក ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា)។ គណៈកម្មការសមាជិកប្រតិបត្តិ តែងតែជួបប្រជុំគ្នាយ៉ាងទៀតទាត់នៅរាល់ ៣ទៅ ៤ខែម្តង ដោយមានការចូលរួមពីសមាជិកទាំងអស់។ សមាជិកគណៈកម្មការទាំងអស់ មានគោលបំណងរួមមួយ គឺខិតខំរក្សាឱ្យបានូវតម្លៃ និងវត្ថុបំណងរបស់ស្ថាប័នខ្លួន អនុវត្តឱ្យបាននូវសុចរិតភាព និងជៀសវាងជម្លោះផលប្រយោជន៍ផ្ទាល់ខ្លួន។

នៅក្នុងកិច្ចប្រជុំពិភាក្សា សមាជិកទាំងអស់ចែករំលែកនូវបទពិសោធន៍ជោគជ័យ ផ្លាស់ប្តូរព័ត៌មាន ឬចំណេះដឹងទៅវិញទៅមក និងលើកឡើងនូវបញ្ហាផ្សេងៗដែលជួបប្រទះ ដើម្បីកែលម្អ និងទទួលបាននូវឱកាសនាពេលអនាគត ដែលនាំមកនូវអត្ថប្រយោជន៍បន្ថែមដល់សមាជិករបស់ខ្លួន។

## វគ្គបណ្តុះបណ្តាលសម្រាប់សមាជិក

**២១ វគ្គបណ្តុះបណ្តាល**

ត្រូវបានរៀបចំឡើង ដោយមានអ្នកចូលរួមចំនួន ៧៩២ នាក់ ត្រូវនឹង ១៣៣ គ្រឹះស្ថានសមាជិក

ដើម្បីគាំទ្រ និងជួយដល់គ្រឹះស្ថានក្នុងការបង្កើនសមត្ថភាពបុគ្គលិករបស់សមាជិកក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ផ្តល់ជូននូវវគ្គបណ្តុះបណ្តាលជារៀងរាល់ខែ ដោយមានការសម្របសម្រួលពីគ្រូបង្វឹកប្រកបដោយបទពិសោធន៍និងជំនាញក្នុងការផ្តល់ការគាំទ្រផ្តល់ជាជំនួយ និងផ្តល់ការណែនាំជាដើម។ វគ្គបណ្តុះបណ្តាលរបស់យើង ធ្វើឡើងដើម្បីឱ្យប្រាកដថាបុគ្គលិកដែលបានចូលរួមទាំងអស់អាចបន្តអភិវឌ្ឍជំនាញ និងសមត្ថភាពរបស់ខ្លួនអោយមានប្រសិទ្ធិភាពជាងមុន និងអាចចូលរួមចំណែកដល់ក្រុមហ៊ុនរបស់ខ្លួនឱ្យអស់ពីសម្ថភាព។

វគ្គបណ្តុះបណ្តាល ក៏ធ្វើឡើងក្នុងគោលបំណងពង្រឹងបន្ថែមនូវការយល់ដឹងកាន់តែច្បាស់អំពីភាពលម្អិតនៃដំណើរការ និងប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក៏ដូចជាទទួលបាន និងតាមដានព័ត៌មាន និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធផងដែរ។ លើសពីនេះទៅទៀត យើងខ្ញុំសង្ឃឹមថា គ្រឹះស្ថានសមាជិកដែលបានចូលរួម អាចប្រើប្រាស់នូវដំណោះស្រាយផ្សេងៗ ដែលបានបង្ហាញក៏ដូចជាបានពិភាក្សាក្នុងវគ្គបណ្តុះបណ្តាល ដើម្បីដោះស្រាយបញ្ហានានា ដែលស្ថាប័នកំពុងជួបប្រទះ។

# សកម្មភាពបុគ្គលិក

## ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក



ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកគឺត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រមួយសម្រាប់ការអភិវឌ្ឍនៅ ស៊ីប៊ីស៊ី។ ពួកយើងបានយល់ដឹងច្បាស់ពីតម្លៃនៃការអភិវឌ្ឍ និងពង្រឹងសមត្ថភាពរបស់បុគ្គលិកយើងម្នាក់ៗ។ យើងដឹងថាការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក គឺមានសារៈសំខាន់ណាស់ ព្រោះវាបានបង្ហាញពីឱកាសដ៏ល្អសម្រាប់បុគ្គលិកក្នុងការអភិវឌ្ឍចំណេះដឹង និងជំនាញការងាររបស់ពួកគេ ដើម្បីឲ្យការបំពេញការងារកាន់តែមានប្រសិទ្ធភាព ។

ស៊ីប៊ីស៊ី បានផ្តល់នូវវគ្គបណ្តុះបណ្តាលជាច្រើន ដែលក្នុងនោះរួមមានការចែករំលែកពីបុគ្គលិកខាងក្នុង កម្មវិធីសិក្សាពីខាងក្រៅ បណ្ណាល័យរបស់ស៊ីប៊ីស៊ី និងកម្មវិធី E-Learning។ ការចែករំលែកពីបុគ្គលិកខាងក្នុង គឺជាបទបង្ហាញពីថ្នាក់ដឹកនាំជាន់ខ្ពស់ ឬបុគ្គលិកចែករំលែកបទពិសោធន៍ និងចំណេះដឹងទៅលើជំនាញ ឬលើការងារដែលពាក់ព័ន្ធ។ រីឯកម្មវិធីសិក្សាពីខាងក្រៅ គឺយើងបញ្ជូនបុគ្គលិកទៅសិក្សានៅខាងក្រៅ ឬប្រើប្រាស់សេវាកម្មបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ ឲ្យមកបង្ហាត់បង្រៀនទៅលើប្រធានបទផ្សេងៗតាមទម្រង់ដែលយើងបានវិភាគពីតម្រូវការវគ្គបណ្តុះបណ្តាល សម្រាប់បុគ្គលិកម្នាក់ៗ។



នៅឆ្នាំ២០២០ ស៊ីប៊ីស៊ីបានរៀបចំវគ្គសិក្សាជាច្រើនលើទាំងជំនាញទ្រឹស្តី និងជំនាញបច្ចេកទេសក្នុងគោលបំណងពង្រឹងជំនាញ បង្កើនប្រសិទ្ធភាព បង្កើនផលិតភាពការងារ និងពង្រីកការលូតលាស់របស់បុគ្គលិក។ បើទោះជាមានកូវីត ១៩ ពួកយើងបានព្យាយាមរៀបចំការចែករំលែកពីបុគ្គលិកខាងក្នុងបាន ៤វគ្គ ដោយជោគជ័យ ដែលសុទ្ធសឹងតែជាប្រធានបទដ៏ពេញនិយមនៅក្នុងវិស័យផ្តល់ព័ត៌មានទិន្នន័យទៅកាន់បុគ្គលិករបស់ពួកយើង។ចំណែកឯកម្មវិធីសិក្សាខាងក្រៅ រួមមានទាំងការសិក្សាលើប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ដែលយើងផ្តោតសំខាន់ទៅគ្រប់ផ្នែកទាំងអស់ រួមទាំងជំនាញចំណេះដឹងលើការងារ ក៏ដូចជាលើជំនាញទ្រឹស្តីរបស់ពួកគេផងដែរ។ នៅក្នុងឆ្នាំ២០២០ ពួកយើងបានបញ្ជូនបុគ្គលិកចំនួន ៣៨នាក់ ទៅសិក្សា ៣៨វគ្គ ដែល ៧០%នៃវគ្គនោះ គឺត្រូវធ្វើឡើងតាមប្រព័ន្ធអ៊ីនធើណិត។កម្មវិធី CBC E-Learning ដែលយើងបានដាក់អោយដំណើរការ កាលពីឆ្នាំ២០១៩ ជាកម្មវិធីមួយ ដែលផ្សព្វផ្សាយពីប្រធានបទផ្សេងៗ និងឆ្លើយតបតាមតម្រូវការរបស់បុគ្គលិក ដែលពួកគេអាចរៀនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ លើសពីនេះទៅទៀត CBC ក៏បានចេញនូវ "បណ្ណាល័យCBC" ជាកន្លែងដែលប្រមូលផ្តុំនូវសៀវភៅ និងមេរៀន ជាឯកសាររឹង និងទន់។ សៀវភៅ និងមេរៀនទាំងនោះ ត្រូវបានរៀបតាមផ្នែកផ្សេងៗគ្នា ដែលជួយសម្រួលដល់បុគ្គលិកយើងក្នុងការស្វែងរកនូវអ្វីដែលពួកគេចង់បាន។

ស៊ីប៊ីស៊ី តែងតែលើកកម្ពស់ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក នៅក្នុងស្ថាប័នព្រោះយើងប្តេជ្ញាថានឹងផ្តល់នូវធនធានចាំបាច់ដែលបុគ្គលិកត្រូវការ ដើម្បីឲ្យពួកគេអាចបំពេញការងារអោយបានល្អបំផុតជាមួយនឹងការគាំទ្រពីប្រធានផ្នែករបស់ពួកគេ និងពីសំណាក់អ្នកគ្រប់គ្រង។

## ការផ្តល់រង្វាន់ និងការទទួលស្គាល់



ការផ្តល់រង្វាន់ និងការទទួលស្គាល់ គឺជារឿងដែលយើងមិនដែលអាក់ខានក្នុងការអបអរសាទរទេ។ ដើម្បីអរគុណដល់បុគ្គលិកដែលខិតខំធ្វើការ យើងធ្វើឲ្យប្រាកដថាការប្រឹងប្រែងរបស់ពួកគេ គឺត្រូវបានឲ្យតម្លៃ។ ជារៀងរាល់ឆ្នាំ ស៊ីប៊ីស៊ី ផ្តល់រង្វាន់ និងការទទួលស្គាល់ចំពោះបុគ្គលិកដែលបានបំពេញការងារ លើសពីការរំពឹងទុក ដូចខាងក្រោម៖

- **បុគ្គលិកឆ្នើមផ្នែកបម្រើសេវាអតិថិជន៖** សំដៅទៅលើរង្វាន់ដែលផ្តល់ឲ្យទៅបុគ្គលិកផ្នែកប្រតិបត្តិការ ដែលពួកគាត់បានខិតខំធ្វើការ លះបង់ពេលវេលា និងប្រឹងប្រែងក្នុងការផ្តល់សេវាដ៏ល្អឥតខ្ចោះទៅកាន់សមាជិករបស់យើង ហើយគាត់ក៏ទទួលបានការគោរពស្រឡាញ់ពីមិត្តរួមការងារក្នុងក្រុមផងដែរ។
- **បុគ្គលិកឆ្នើមផ្នែកលក់ប្រចាំឆ្នាំ៖** សំដៅទៅលើរង្វាន់ដែលផ្តល់ឲ្យទៅបុគ្គលិកផ្នែកអភិវឌ្ឍន៍អាជីវកម្ម ដែលបានបង្កើតប្រាក់ចំណូលហួសពីការរំពឹងទុក។
- **បុគ្គលិកឆ្នើមប្រចាំឆ្នាំ៖** សំដៅទៅលើទាំងប្រធានផ្នែក ឬបុគ្គលិក ដែលធ្វើបំពេញតួនាទីលើសពីការរំពឹងទុក។ យើងមាន ៥ ចំនុច ក្នុងការវិនិច្ឆ័យ៖ ការបំពេញការងារ ការចែករំលែក ការចូលរួម ការជំរុញទឹកចិត្ត និងគំនិតច្នៃប្រឌិត។









## ការរួបរួមគ្នាជាក្រុម



ដើម្បីឲ្យច្បាស់ថាបុគ្គលិកយើងដើរស្របជាមួយនឹងគោលដៅរបស់ក្រុមហ៊ុន និងដើម្បីឲ្យមានភាពសប្បាយរីករាយ ស៊ីប៊ីស៊ី តែងតែមានកម្មវិធីជួបជុំខ្លះៗនៅក្នុងឆ្នាំនីមួយៗ ដែលកម្មវិធីនោះរួមមានដូចជា ការប្រជុំ Townhall និងដំណើរកម្សាន្តប្រចាំឆ្នាំ។ដំណើរកម្សាន្តប្រចាំឆ្នាំរបស់យើង គឺរៀបចំឡើងមិនមែនសម្រាប់តែការសប្បាយរីករាយទៅតែមួយមុខទេ ប៉ុន្តែដើម្បីពង្រឹងការទុកចិត្តគ្នា ការធ្វើការជាក្រុមបង្កើនទំនាក់ទំនង និងបង្កើនភាពស្និតស្នាលរវាងបុគ្គលិកទាំងអស់។ បើទោះបីជាមានផលលំបាកជាមួយនឹងកូវីដ ១៩ ពួកយើងបានព្យាយាមអស់ពីលទ្ធភាពក្នុងការរៀបចំកម្មវិធីមួយចំនួននៅក្នុងឆ្នាំ២០២០ ដើម្បីលើកទឹកចិត្តបុគ្គលិករបស់យើង។

នៅខែសីហា ឆ្នាំ២០២០ ស៊ីប៊ីស៊ី បានធ្វើការសំណេះសំណាលប្រចាំឆមាសនៅសណ្ឋាគារដ៏ល្បីឈ្មោះមួយនៅទីក្រុងភ្នំពេញ។ ការសំណេះសំណាល គឺធ្វើឡើងដើម្បីឲ្យបុគ្គលិកយើងយល់ដឹងពីបច្ចុប្បន្នភាពនៃដំណើរការអាជីវកម្ម និងគម្រោងដែលយើងមានសម្រាប់៦ខែខាងមុខទៀត អមជាមួយនឹងល្បែងកំសាន្ត អាហារពេលថ្ងៃដ៏ឆ្ងាញ់ពិសារ និងការធ្វើបទបង្ហាញពីថ្នាក់ដឹកនាំជាន់ខ្ពស់។

នៅដើមខែវិច្ឆិកា ឆ្នាំ២០២០ ស៊ីប៊ីស៊ីបានរៀបដំណើរកំសាន្តប្រចាំឆ្នាំទៅកាន់ខេត្តសៀមរាប។ ដំណើរកំសាន្តរយៈពេល ៣ ថ្ងៃ នេះ គឺពិតជាគួរឲ្យចងចាំ ដោយយើងបានចំណាយពេលមួយថ្ងៃចូលរួមជាមួយនឹងកម្មវិធីនៃការជួយសង្គមដែលបានរៀបចំដោយសមាគមធនាគារនៅកម្ពុជា ដែលពួកយើងបានជិះកង់ចម្ងាយ ១៨គ.ម នៅទីលានជល់ដំរី។ កម្មវិធីនេះបានឆ្លុះបញ្ចាំង ២ចំណុចធំៗ ទីមួយ គ្មាននរណាត្រូវបានទុកចោល និងចំណុចទីពីរ ការបំពេញការងាររបស់ក្រុម គឺត្រូវគេកំណត់ជាលទ្ធផលទៅលើអ្នកដែលនៅក្រោយគេ។ ហើយពួកយើងក៏មានការទទួលទានអាហារពេលល្ងាច ដែលអមជាមួយនឹងល្បែងកំសាន្ត រង្វាន់ និងការជប់លៀងផងដែរ។





# ការប្តេជ្ញា និងទំនួលខុសត្រូវ

## ការពិភាក្សាចែករំលែកជាមួយអតិថិជន៖ ការផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុ និងសិទ្ធរបស់អតិថិជនក្នុងរបាយការណ៍ឥណទាន



ការពិភាក្សាអំពីការចែករំលែកចំណេះដឹងជាមួយអតិថិជន គឺជាវេទិកាមួយដែល ស៊ីប៊ីស៊ី និងអតិថិជនទូទៅអាចចែករំលែក និងពិភាក្សាគ្នាអំពីព័ត៌មានសំខាន់ៗទាក់ទងទៅនឹងរបាយការណ៍ឥណទាន។ កម្មវិធីនេះផ្តោតសំខាន់ទៅលើអ្នកដែលកំពុងប្រើប្រាស់កម្ចី ឬ មានគម្រោងនឹងប្រើប្រាស់កម្ចី ឬចង់ដឹងព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃរបាយការណ៍ឥណទាន។

គោលបំណងនៃវេទិកានេះ គឺចែករំលែកនូវចំណេះដឹងពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់នៃការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាននៅក្នុងប្រទេសកម្ពុជា របៀបអានរបាយការណ៍ឥណទាន សារៈសំខាន់នៃរបាយការណ៍ឥណទាន និងវិធីសាស្ត្ររក្សានូវព័ត៌មានល្អក្នុងរបាយការណ៍ឥណទាន។

ទោះបីជានៅក្នុងឆ្នាំ២០២០ មានជំងឺកូវីដ ១៩ ក្តី ក៏ ស៊ីប៊ីស៊ី នៅតែអាចរៀបចំការពិភាក្សាអំពីការចែករំលែកចំណេះដឹងជាមួយអតិថិជនតាមរយៈវេទិកាអនឡាញ នៅក្នុងត្រីមាសទី៣ផងដែរ ដោយមានអ្នកចូលរួមចំនួន ២៧នាក់ មកពីស្ថាប័នធនាគារ និងហិរញ្ញវត្ថុ អចលនទ្រព្យ ក្រុមហ៊ុនបញ្ចាំ សិស្ស និងស្ថាប័នឯកជនមួយចំនួនទៀតផងដែរ។

ដើម្បីចូលរួមលើកកម្ពស់ និងបង្កើនចំណេះដឹងជូនដល់អតិថិនជនលើផ្នែកនេះ យើងខ្ញុំនឹងបន្តក្នុងការរៀបចំវេទិកានេះទៀតនៅក្នុងឆ្នាំ ២០២១ តាមរយៈប្រព័ន្ធអនឡាញ។





## វិញ្ញាបនបត្រកម្រិតមាសនៃអនុលោមសារពើពន្ធ





ស៊ីប៊ីស៊ី បានទទួលនូវវិញ្ញាបនបត្រអនុលោមសារពើពន្ធកម្រិតមាសពីអគ្គនាយកដ្ឋានពន្ធដារ។ វិញ្ញាបនបត្រនេះបានផ្តល់ជូនក្រុមហ៊ុនដោយផ្អែកទៅលើការវាយតម្លៃរបស់អគ្គនាយកដ្ឋានពន្ធដារពីកាតព្វកិច្ចបង់ពន្ធស្របតាមគោលការណ៍ ការទូទាត់បង់ពន្ធតាមកាលកំណត់ និងផ្តល់ឯកសារត្រឹមត្រូវ។

## ការពិភាក្សាពេលព្រឹកៈ ភាពដឹកនាំលើប្រព័ន្ធឌីជីថល ការវិភាគទិន្នន័យ និងការគ្រប់គ្រងហានិភ័យឥណទាន











ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី បានរៀបចំកម្មវិធី ការពិភាក្សាពេលព្រឹកលើកទីមួយ ដោយបានអញ្ជើញថ្នាក់ដឹកនាំជា ៥០នាក់ ពីវិស័យហិរញ្ញវត្ថុ ដើម្បីពិភាក្សាទៅលើនិន្នាការក្នុងការទាញយកប្រយោជន៍ពីប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងហានិភ័យឥណទាន។ កម្មវិធីនេះ ត្រូវបានធ្វើឡើងនៅសណ្ឋាគារ Rosewood ភ្នំពេញ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានការចូលរួមពីសំណាក់អ្នកមានបទពិសោធន៍ និងតំណាងឲ្យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នផ្សេងទៀត។ កម្មវិធីនេះ ក៏បានផ្សាយផ្ទាល់ជូនទៅកាន់ស្ថាប័នដែលជាសមាជិករបស់ស៊ីប៊ីស៊ីផងដែរ។

ការបើកសុន្ទរកថាដោយលោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា និងជាប្រធានក្រុមប្រឹក្សានៃក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ផងដែរ លោកជំទាវបានសង្កត់ធ្ងន់ទៅលើប្រធានបទពាក់ព័ន្ធទៅនឹងឌីជីថល ព្រមទាំងការគ្រប់គ្រងលើហានិភ័យឥណទាន។ ចំពេលដែលមានការរីករាលដាលនៃវីរុសកូវីដ ១៩ ទីផ្សារឥណទានមានការប៉ះពាល់ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច ហើយស្ថាប័នហិរញ្ញវត្ថុ គឺកំពុងតែឆ្ពោះទៅរកការផ្តល់ជូនអតិថិជនតាមប្រព័ន្ធឌីជីថល។

កញ្ញា Ratana Phurik-Callebuat ជាអ្នកប្រឹក្សាជាន់ខ្ពស់ផ្នែកវិនិយោគក្នុងវិស័យឯកជន បានធ្វើជាអ្នកសម្របសម្រួលនៃកិច្ចពិភាក្សាជាមួយនឹងអ្នកជំនាញ លើប្រធានបទ ការប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រងហានិភ័យឥណទាន។ វាគ្មិនកិត្តិយសក្នុងកម្មវិធីនេះ មានដូចជា លោក គា បូរាណ ប្រធាននាយកប្រតិបត្តិ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ លោក Malay Kumer Pau អនុប្រធាននាយកប្រតិបត្តិនៃធនាគារប្រៃសណីយ៍កម្ពុជា លោក Shing Chang Moo នាយកប្រតិបត្តិ នៃធនាគារ PPCBank ព្រមទាំងលោក Stephen Higgins ដែលជា អ្នកគ្រប់គ្រងដៃគូសហការនៃ Mekong Strategic Partner ។



## ការឧបត្ថម្ភដល់កម្មវិធីវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោកឆ្នាំ2020៖ ប្រមូលផ្តុំដោយអ្នកដឹកនា និងអ្នកជំនាញក្នុងវិស័យហិរញ្ញវត្ថុ និងបច្ចេកវិទ្យា

ស៊ីប៊ីស៊ី បានឧបត្ថម្ភកម្មវិធីវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោក ដែលជាកម្មវិធីប្រមូលផ្តុំដោយអ្នកដឹកនា និងអ្នកជំនាញក្នុងវិស័យហិរញ្ញវត្ថុ និងបច្ចេកវិទ្យា រៀបចំដោយ៣៥ប្រទេសជុំវិញពិភពលោក។ ។
កម្មវិធីនេះ មានរយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ រៀបចំដោយ Singapore Fintech Festival សហការជាមួយនឹងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា ធនាគារជាតិកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ព្រមទាំងមានវាគ្មិនជាតិ និងអន្តរជាតិ ពិភាក្សាអំពីស្ថានភាពវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា រួមមានការកើនឡើងនៃរូបិយប័ណ្ណឌីជីថល ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ បរិយាប័ន្នហិរញ្ញវត្ថុ ទស្សនៈវិស័យនៃសេដ្ឋកិច្ចនាពេលអនាគត និងផ្នែកផ្សេងៗទៀត។ កម្មវិធីនេះផ្តល់ឱកាសដល់អ្នកចូលរួមបង្កើតទំនាក់ទំនង និងសហការគ្នា។យ៉ាងណាមិញដោយសារតែមានការរាតត្បាតនៃវីរុស ការពិភាក្សានេះត្រូវបានធ្វើតាមប្រព័ន្ធអនឡាញ ដែលមានស៊ីប៊ីស៊ីជាអ្នកសម្របសម្រួល។




## នវានុវត្តន៍ប្រព័ន្ធឌីជីថល និងការបង្កើតប្រព័ន្ធអេកូអាជីកម្មបង្កើតថ្មី តាមរយៈគំរូនវានុវត្តន៍បញ្ច្រាស




ស៊ីប៊ីស៊ី ក៏បានឧបត្ថម្ភកម្មវិធីនវានុវត្តន៍បញ្ច្រាសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ច "តេជោ" ដែលជាស្ថាប័នរដ្ឋបាលសាធារណៈមួយ មានភារៈកិច្ចក្នុងការបង្កើតនូវអាជីវកម្មបង្កើតថ្មីតាមបែបបច្ចេកវិទ្យា និងនវានុវត្តន៍ ដែលអាចពង្រីកប្រតិបត្តិការរបស់ខ្លួនបាន ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រព័ន្ធសេដ្ឋកិច្ចតាម បែបឌីជីថលឲ្យកាន់តែរឹងមាំ ។ នៅក្នុងកម្មវិធីនេះ ក្រុមហ៊ុនធំៗ បានធ្វើបទបង្ហាញពីបញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយដែលល្អប្រសើរជាងនេះ ខុសពីកម្មវិធីផ្សេងទៀត ដែលតម្រូវឲ្យម្ចាស់អាជីវកម្មថ្មីស្វែងរកនូវបញ្ហាដោយខ្លួនឯង ហើយដោះស្រាយបញ្ហានោះ។ ម៉ូឌែល RI ត្រូវបានលើកឡើងដំបូង ដោយសាស្ត្រចារ្យ ២នាក់មកពីសាកលវិទ្យាល័យ Havard ជាមួយបច្ចេកវិទ្យាដែលប្រទេសអភិវឌ្ឍន៍ អាចជួយដោះស្រាយបញ្ហារបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ម៉ូឌែល RI នៅក្នុងប្រទេសកម្ពុជា ធ្វើឡើងដើម្បីជួយដោះស្រាយបញ្ហាក្រុមហ៊ុនធំៗ ដែលត្រូវការនវានុវត្តន៍ ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែង ផ្តល់នូវឱកាសសម្រាប់អ្នកចាប់ផ្តើមអាជីវកម្មបង្កើតថ្មី ដើម្បីទទួលបានការវិនិយោគ និងចូលរួមចំណែកបង្កើតប្រព័ន្ធអេកូអាជីកម្មបង្កើតថ្មី។

ក្រៅពីការឧបត្ថម្ភជា Platinum ស៊ីប៊ីស៊ី ក៏បានធ្វើបទបង្ហាញបញ្ហាប្រឈមពីរ ដែលទាក់ទងនឹង EKYC និងពិន្ទុឥណទានពីវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា សម្រាប់អាជីវកម្មបង្កើតថ្មីក្នុងការស្វែងរកដំណោះស្រាយផងដែរ។

## គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី សម្រាប់ស្ថិរភាពវិស័យហិរញ្ញវត្ថុនៅកម្ពុជា

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងនូវស្ថានភាពបំណុលវណ្ឌកនៅកម្ពុជា ស៊ីប៊ីស៊ី បានចូលរួមជាមួយនឹងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអ្នកឧបត្ថម្ភផ្សេងទៀត ក្នុងការបង្កើតគោលការណ៍ណែនាំអំពីការផ្តល់ប្រាក់កម្ចី និងការត្រួតពិនិត្យអំពីការអនុលោមតាមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាំងពីឆ្នាំ២០១៦ មកម្ល៉េះ។ គោលការណ៍ណែនាំអំពីការផ្តល់ប្រាក់កម្ចីនេះ គឺជាយន្តការដើម្បីលើកកម្ពស់ការផ្តល់ឥណទាន ដែលអាចកាត់បន្ថយនូវហានិភ័យទីផ្សារ ធានាឲ្យបានថាការវាយតម្លៃពីលទ្ធភាពសងរបស់អតិថិជនបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយក្នុងគោលបំណងតាមដានផលប៉ះពាល់ទៅកាន់ស្ថាប័ន និងវិស័យទាំងមូល។

នៅក្នុងដំណាក់កាលទី៣នេះ ក្រុមការងារបានកែប្រែនូវសូចនាករមួយចំនួនលើគោលការណ៍ណែនាំនេះ និងពង្រីកឲ្យកាន់តែមានភាពទូលំទូលាយក្នុងវិស័យហិរញ្ញវត្ថុទាំងមូល។




## ការពង្រឹងអភិបាលកិច្ចនៃគ្រឹះស្ថានឥណទានជនបទ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា







ស៊ីប៊ីស៊ី បានសហការជាមួយនឹងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីរៀបចំនូវសិក្ខាសាលាចែករំលែកចំណេះដឹង ទៅកាន់គ្រឹះស្ថានឥណទានជនបទចំនួន ២៥ ក្នុងឆ្នាំ២០២០ ដើម្បីតាមដានលទ្ធផល និងយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឥណទានជនបទដែលអាចជួយពង្រឹងនូវអភិបាលកិច្ចរបស់ពួកគេសម្រាប់ស្ថិរភាពវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

គ្រឹះស្ថានឥណទានជនបទ ត្រូវតែមានចំណេះដឹង និងឧបករណ៍គ្រប់គ្រាន់ ដើម្បីពង្រឹងសម្ថភាពរបស់ពួកគេ ក្នុងការទប់ស្កាត់នូវបញ្ហាប្រឈម និងការប្រកួតប្រជែង។ ស៊ីប៊ីស៊ី គាំទ្រយ៉ាងពេញទំហឹងទៅដល់គ្រឹះស្ថានឥណទានជនបទ ដាក់អោយប្រើប្រាស់នូវ CIRFS ដើម្បីពង្រឹងការធ្វើរបាយការណ៍ និងប្រព័ន្ធអភិបាលកិច្ចរបស់ពួកគេ។

# ៥. ស្ថានភាពជារួមនៃទីផ្សារ ឥណទាននៅប្រទេសកម្ពុជា

# សូចនាករសំខាន់ៗនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា

| ប្រភេទ | សូចនាករ | ២០១៩ | ២០២០ |
|---|---|---|---|
| លទ្ធផល និង កំណើនសេដ្ឋកិច្ច | ផ.ស.ស (កោដិដុល្លារ) | ២៦.៧ | ២៦ |
| | អត្រាកំណើនផលិតផលក្នុងស្រុកសរុប (ភាគរយប្រចាំឆ្នាំ) | ៧.១ | -៤** |
| | ផ.ស.ស/ប្រជាជនសរុប (ដុល្លារ) | ១,៧១០ | ១,៦៦០ |
| រូបិយវត្ថុ និងតម្លៃ | អតិផរណា (ភាគរយប្រចាំឆ្នាំ) | ២ | ២.៩ |
| | ទុនបង្វិល (ភាគរយនៃផ.ស.ស) | ៩៦.៦ | ១២៩.៦ |
| | អត្រាកំណើននៃទុនបង្វិល (ភាគរយប្រចាំឆ្នាំ) | ១៧.៩ | ៣០.៩ |
| | ឥណទានក្នុងស្រុកសម្រាប់វិស័យឯកជន (ភាគរយនៃផ.ស.ស) | ១១៨.៨ | ១៤៣ |
| | ប្រាក់បញ្ញើសរុបក្នុងប្រព័ន្ធធនាគារ (កោដិដុល្លារ) | ២៥.៦០ | ២៩.៩៩ |
| | អត្រាប្តូរប្រាក់ឈ្មួញមធ្យម (រៀលក្នុងមួយដុល្លារ) | ៤,០៧០ | ៤,០៥០ |
| | អត្រាការប្រាក់រយៈពេលខ្លី (ភាគរយប្រចាំឆ្នាំ) | ៩.៥* | ៩.៣** |

| ប្រភេទ | សូចនាករ | ២០១៩ | ២០២០ |
|---|---|---|---|
| កត្តារួមចំណែកពីខាងក្រៅ | កំណើនការនាំចេញ (ជាភាគរយ) | ៩.៥* | -១៨.៥** |
| | កំណើនការនាំចូល (ជាភាគរយ) | ៩.០* | -១៧.៨** |
| | ការនាំចេញទំនិញ (ភាគរយនៃផ.ស.ស) | ៥៦.៤ | ៦៧.៧ |
| | ការនាំចូលទំនិញ (ភាគរយនៃផ.ស.ស) | ៨៣.៧ | ៨១.៦ |
| | សេវាកម្មដុល (ភាគរយនៃផ.ស.ស) | ១០.៦ | -០.៥ |
| | ចំណូលដុល (ភាគរយនៃផ.ស.ស) | ១.៤ | ២.៥ |
| | សមតុល្យគណនីបច្ចុប្បន្ន (កោដិដុល្លារ) | -៤,០៧៧ | -៣,០៨៩ |
| | សមតុល្យគណនីបច្ចុប្បន្ន (ភាគរយនៃផ.ស.ស) | -១៥.៣ | -១១.៩ |
| | វិនិយោគផ្ទាល់ពីបរទេស លំហូរដុល (លានដុល្លារ) | ២,៨៤៥* | ២,៣២៨** |
| | ទុនបំរុងអន្តរជាតិ (លានដុល្លារ) | ១៨,៧៣២* | ១៦,៨៥៩** |

*ប្រភព: ធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងមូលនិធិរូបិយបត្រអន្តរជាតិ*
** អត្រាការប្រាក់ ១ ដុល្លារស្មើរ ៤,០៤៥ រៀល ត្រូវបានអនុវត្ត*
** និង** បង្ហាញពីការរំពឹងទុក និងការព្យាករណ៍របស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី*

# ស្ថានភាពទីផ្សារ
# ឥណទានបុគ្គលនៅកម្ពុជា

បើប្រៀបធៀបទៅនឹងឆ្នាំមុន ទីផ្សារឥណទានបុគ្គលនៅកម្ពុជា មានសភាពថមថយជាងមុន ដោយនៅឆ្នាំ២០២០នេះ ការស្នើរសុំឥណទាន បានធ្លាក់ចុះចំនួន៧.៥%។ ស្របពេលជាមួយនឹងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច គុណភាពនៃឥណទានដែលវាស់ដោយភាគរយនៃឥណទានមិនដំណើរការលើសពី ៣០ ថ្ងៃ (៣០ + DPD) ក៏ឃើញមានការកើនឡើងដល់ ១.៦៩% (កើនឡើងចំនួន ០.៤២%) ផងដែរ។ ទោះបីជាមានការប្រឈមមួយចំនួន ទីផ្សារឥណទាននៅតែមានកំណើនរឹងមាំដោយចំនួនអ្នកប្រើប្រាស់ឥណទានកើនឡើងចំនួន ៨% រីឯចំនួនគណនីឥណទានកើនឡើង ៤%។

៧៥%នៃអ្នកប្រើប្រាស់ឥណទាន ស្ថិតនៅក្រុមអាយុ ២០-៤៩ ឆ្នាំ។ នៅក្នុងផលប័ត្រកម្ចីសរុប ស្ត្រីជាអ្នកប្រើប្រាស់ឥណទានច្រើនជាងគេ ដែលមានចំណែកដល់ទៅ ៥៤% ហើយស្ថិតនៅក្រុមអាយុ ១៩-៦៩ ឆ្នាំ ។ ជាងពាក់កណ្ដាលនៃចំនួនអ្នកប្រើប្រាស់ឥណទាន ស្ថិតនៅតំបន់ទំនាប។ នៅតាមខេត្ត/ក្រុង អត្រាអ្នកប្រើប្រាស់ឥណទានដែលខ្ពស់ជាងគេ គឺជាអ្នកនៅទីក្រុងភ្នំពេញ ដែលមានដល់ទៅ ១២.២៨%នៃចំនួនសរុប។ បន្ទាប់មក គឺខេត្តកណ្ដាល កំពង់ស្ពឺ សៀមរាប តាកែវ និងព្រៃវែង។

១៦% នៃកម្ចីសរុប ជាកម្ចីអចលនទ្រព្យ ដែលមានភាគរយនៃឥណទានមិនដំណើរការលើសពី ៣០ ថ្ងៃ (៣០ + DPD) ទាបជាងគេគឺ ០.៩៣%។ កម្ចីអាជីវកម្មខ្នាតតូចមានចំណែកក្នុងផលប័ត្រកម្ចីខ្ពស់បំផុត គឺប្រមាណ ៦១% នៃចំនួនសមតុល្យឥណទានសរុបដែលមានចំណាត់ថ្នាក់នៃឥណទានមិនដំណើរការលើសពី ៣០ ថ្ងៃ (៣០ + DPD) ទីពីរ គឺ ១.៥%។ ៣០ + DPD ខ្ពស់បំផុតគឺ ២.៩២% ដែលសង្កេតឃើញនៅក្នុងកម្ចីលក្ខណៈបុគ្គល ដែលមានចំនួន១៤% នៃផលប័ត្រសរុប។

| ចំនួនអ្នកប្រើប្រាស់ឥណទាន | ចំនួនគណនីឥណទាន | ចំនួនពាក្យស្នើសុំឥណទាន | ភាគរយនៃឥណទាន មិនដំណើរការលើសពី ៣០ ថ្ងៃ (៣០ + DPD) |
|---|---|---|---|
| ៧.៩៣% | ៤.១៣% | ៧.៥៣% | ០.៤២% |

# ស្ថានភាពឥណទានក្នុងតំបន់

តំបន់ទំនាប គឺជាតំបន់ដែលមានឥណទានច្រើនបំផុត។ ក្នុងនោះ ៧០% នៃ សមតុល្យឥណទានសរុប និង ៥៦%នៃ ចំនួនអ្នកប្រើប្រាស់ឥណទាន គឺស្ថិតនៅតំបន់នេះ។

តំបន់ទន្លេបសាបមានប្រមាណ ២១% នៃសមតុល្យឥណទានសរុប ស្មើនឹង ៣១% នៃចំនួនអ្នកប្រើប្រាស់ឥណទានសរុប។ តំបន់ឆ្នេរសមុទ្រមានចំនួន ៥% នៃសមតុល្យឥណទានសរុប ស្មើនឹង ៧% នៃចំនួនចំនួនអ្នកប្រើប្រាស់ឥណទានសរុប។

តំបន់ខ្ពង់រាបមានចំនួន ៤% នៃសមតុល្យឥណទានសរុប ស្មើនឹង ៧% នៃចំនួនអ្នកប្រើប្រាស់ឥណទានសរុប។

កំណើននៃវត្ថុមានរបស់ស្ថាប័នហិរញ្ញវត្ថុនៅតាមតំបន់គឺមានតុល្យភាពរវាងពី ២១% នៅខ្ពង់រាប និង ២៩% នៅតំបន់ទំនាប។

## សមតុល្យឥណទានសរុប




**តំបន់ទំនាប**
$២២.៤២ ពាន់លាន
**២០%**

**តំបន់ទន្លេសាប**
$៦.៨១ ពាន់លាន
**១៩%**

**តំបន់ខ្ពង់រាប**
$១.១៧ ពាន់លាន
**២២%**

**តំបន់ឆ្នេរសមុទ្រ**
$១.៧៤ ពាន់លាន
**១៥%**

## ចំនួនគណនីឥណទាន




| | |
|---|---|
| តំបន់ទំនាប<br>$១.៩៤ លាន<br>២% | តំបន់ទន្លេសាប<br>$១.១២ លាន<br>៦% |
| តំបន់ខ្ពង់រាប<br>$០.២៤ លាន<br>៩% | តំបន់ឆ្នេរសមុទ្រ<br>$០.២៣ លាន<br>៣% |

## ចំនួនអ្នកប្រើប្រាស់ឥណទាន




| | |
|---|---|
| តំបន់ទំនាប<br>$២.៣៣ លាន<br>៦% | តំបន់ទន្លេសាប<br>$១.៣១ លាន<br>១០% |
| តំបន់ខ្ពង់រាប<br>$០.២៨ លាន<br>១៣% | តំបន់ឆ្នេរសមុទ្រ<br>$០.២៨ លាន<br>៩% |

# តំបន់ទន្លេសាប

**៨**
ខេត្ត

**៦,៨១៥.៤ លានដុល្លារ**
សមតុល្យឥណទានសរុប

**១៤៧**
ស្ថាប័នហិរញ្ញវត្ថុ

**១,៣០៩ ពាន់នាក់**
ចំនួនអ្នកប្រើប្រាស់ឥណទាន




## ឧត្តរមានជ័យ

**២៨៣.៨ លានដុល្លារ** សមតុល្យឥណទានសរុប
**៧៨.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## សៀមរាប

**១,៩២២.៦ លានដុល្លារ** សមតុល្យឥណទានសរុប
**២៩០.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## បន្ទាយមានជ័យ

**១,២២០.៥ លានដុល្លារ** សមតុល្យឥណទានសរុប
**១៩១.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## បាត់ដំបង

**១,៣៦៨.៧ លានដុល្លារ** សមតុល្យឥណទានសរុប
**២៦៣.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## ប៉ៃលិន

**១៣៤.១ លានដុល្លារ** សមតុល្យឥណទានសរុប
**២២ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## ពោធិសាត់

**៥២២.៩ លានដុល្លារ** សមតុល្យឥណទានសរុប
**១១៧.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## កំពង់ធំ

**៦៨៨.៤ លានដុល្លារ**
សមតុល្យឥណទានសរុប
**២២០.០ ពាន់នាក់**
ចំនួនអ្នកប្រើប្រាស់ឥណទាន

## កំពង់ឆ្នាំង

**៥០៤.៨ លានដុល្លារ** សមតុល្យឥណទានសរុប
**១៣០.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

# តំបន់ខ្ពង់រាប

៥
ខេត្ត

១,១៧០.៥ លានដុល្លារ
សមតុល្យឥណទានសរុប

១១៥
ស្ថាប័នហិរញ្ញវត្ថុ

២៧៩ ពាន់នាក់
ចំនួនអ្នកប្រើប្រាស់ឥណទាន




## ព្រះវិហារ

**២៥៥.៧ លានដុល្លារ** សមតុល្យឥណទានសរុប
**៧២.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## ស្ទឹងត្រែង

**១៤៦.៥ លានដុល្លារ** សមតុល្យឥណទានសរុប
**៣២ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## រតនគិរី

**៣០៨.៣ លានដុល្លារ** សមតុល្យឥណទានសរុប
**៥៩.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## មណ្ឌលគិរី

**១២១.៦ លានដុល្លារ** សមតុល្យឥណទានសរុប
**២៣.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## ក្រចេះ

**៣៣៨.៣ លានដុល្លារ** សមតុល្យឥណទានសរុប
**៩៣ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

# តំបន់ទំនាប

៨
ខេត្ត

២២,៣២៩.៦ លានដុល្លារ
សមតុល្យឥណទានសរុប

១៦០
ស្ថាប័នហិរញ្ញវត្ថុ

២,៣៣៥ ពាន់នាក់
ចំនួនអ្នកប្រើប្រាស់ឥណទាន




## ភ្នំពេញ

១៣,៩៣១.៥ លានដុល្លារ សមតុល្យឥណទានសរុប
៥១៦.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## កំពង់ស្ពឺ

១,៤៦៧.៧ លានដុល្លារ សមតុល្យឥណទានសរុប
៣០០.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## តាកែវ

១,២៨៦.៩ លានដុល្លារ សមតុល្យឥណទានសរុប
២៨០.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## កណ្តាល

១,៩០៥.៥ លានដុល្លារ សមតុល្យឥណទានសរុប
៣៣៨.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## កំពង់ចាម

១,២១៤.៧ លានដុល្លារ
សមតុល្យឥណទានសរុប
២៦៦.០ ពាន់នាក់
ចំនួនអ្នកប្រើប្រាស់ឥណទាន

## ត្បូងឃ្មុំ

៧៣៦.៨ លានដុល្លារ សមតុល្យឥណទានសរុប
១៨០.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## ព្រៃវែង

១,០៦១.១ លានដុល្លារ សមតុល្យឥណទានសរុប
២៧៦.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

## ស្វាយរៀង

៨២៥.៣ លានដុល្លារ សមតុល្យឥណទានសរុប
១៧៨.០ ពាន់នាក់ ចំនួនអ្នកប្រើប្រាស់ឥណទាន

# តំបន់ឆ្នេរសមុទ្រ

៤
ខេត្ត

១,៧៤២.៤ លានដុល្លារ
សមតុល្យឥណទានសរុប

១៣៦
ស្ថាប័នហិរញ្ញវត្ថុ

២៨២ ពាន់នាក់
ចំនួនអ្នកប្រើប្រាស់ឥណទាន




## កោះកុង

**២១៤.៧ លានដុល្លារ** សមតុល្យឥណទានសរុប
**៣៤.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## ព្រះសីហនុ

**៦៣៣.២ លានដុល្លារ** សមតុល្យឥណទានសរុប
**៦៣.៦ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## កំពត

**៨៣៧.៨ លានដុល្លារ** សមតុល្យឥណទានសរុប
**១៧៣.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

## កែប

**៥៦.៨ លានដុល្លារ** សមតុល្យឥណទានសរុប
**១១.០ ពាន់នាក់** ចំនួនអ្នកប្រើប្រាស់ឥណទាន

# ខេត្តទាំង១០ ដែលមានកំណើនច្រើនជាងគេ

គេសង្កេតឃើញមានខេត្ត ១០ ដែលមានកំណើនសមតុល្យឥណទានសរុបកើនឡើងចន្លោះ ២១ ទៅ ៣៦% ក្នុងឆ្នាំ ២០២០ ហើយខេត្តព្រះវិហារ ឈរលំដាប់លេខ១ បន្ទាប់មកខេត្តកោះកុង លំដាប់លេខ២ និងខេត្តស្ទឹងត្រែង ឈរលំដាប់លេខ៣។




គេសង្កេតឃើញមានខេត្ត ១០ ដែលមានកំណើនអ្នកប្រើប្រាស់ឥណទាន កើនឡើងចន្លោះ ១០ ទៅ ១៧% ក្នុងឆ្នាំ ២០២០ ហើយខេត្តព្រះវិហារ ឈរលំដាប់លេខ១ បន្ទាប់មកខេត្តស្ទឹងត្រែង ឈរលំដាប់លេខ២ រីឯខេត្តកែប ឈរលំដាប់លេខ៣។



# ស្ថានភាពប្រជាសាស្រ្តនៃឥណទាន

៥៤%នៃអ្នកប្រើប្រាស់ឥណទានជាស្ត្រីនិង៤៦%ជាបុរស។ អ្នកប្រើប្រាស់ឥណទានដែលស្ថិតនៅក្នុងក្រុមអាយុពី៣០-៣៩ មានច្រើនជាងគេ គឺ ៣៣%។ ហើយក្រុមអាយុ ២០-៤៩ មាន៧៥% នៃចំណែកអ្នកប្រើប្រាស់ឥណទានសរុប ។




ភាគរយនៃចំនួនអតិថិជនប្រើប្រាស់ឥណទានតាមក្រុមអាយុ



# ការស្នើសុំឥណទាន

**- ៧.៥ %**
ភាគរយនៃកំណើនចំនួនស្នើសុំឥណទានក្នុងឆ្នាំ ២០២០

**- ០.៨ %**
ភាគរយនៃទឹកប្រាក់ឥណទានសរុប

ការស្នើសុំឥណទានបញ្ជាក់ពីបំណងរបស់អ្នកប្រើប្រាស់ដើម្បីទទួលបានឥណទាន។ កំណើននៃការដាក់ពាក្យស្នើសុំឥណទាន បង្ហាញពីការកើនឡើងនូវតម្រូវការឥណទាន និងជាសញ្ញាបង្ហាញពីទីផ្សាររស់រវើក។ កំណើនប្រចាំឆ្នាំមានការធ្លាក់ចុះចំនួន ៧.៥% នៃចំនួនពាក្យស្នើសុំឥណទាន រីឯចំនួនទឹកប្រាក់សរុបដែលបានស្នើសុំក៏ធ្លាក់ចុះចំនួន០.៨%ផងដែរ។ ខណៈពេលដែលចំនួននៃការដាក់ពាក្យស្នើសុំឥណទានមានការប្រែប្រួលតាមត្រីមាស ចំនួនទឹកប្រាក់ឥណទានសរុបដែលបានស្នើសុំជាមធ្យមកើនឡើងនៅទូទាំងត្រីមាស។

### ភាគរយនៃកំណើននៃចំនួនការស្នើសុំឥណទានតាមត្រីមាស




### ភាគរយនៃកំណើននៃប្រាក់នៃការស្នើសុំឥណទានតាមត្រីមាស




### ភាគរយនៃកំណើនចំនួនទឹកប្រាក់សរុបស្នើសុំជាមធ្យមតាមត្រីមាស



# កំណើននៃដំណើរការឥណទាន

ដំណើរការឥណទាន បង្ហាញអំពីស្ថានភាពប្រាក់កម្ចីជាក់ស្តែងគិតត្រឹមឆ្នាំចេញរបាយការណ៍ដើម្បីបញ្ជាក់ពីកម្រិតសកម្មនៃទីផ្សារឥណទាន។

### + ១៩.២៨% សមតុល្យឥណទានសរុបក្នុងឆ្នាំ ២០២០

*ភាគរយនៃកំណើននៃសមតុល្យឥណទាន តាមត្រីមាស*




### + ៤% ចំនួនគណនីឥណទានក្នុងឆ្នាំ ២០២០

*ភាគរយនៃកំណើននៃចំនួនគណនីឥណទាន តាមត្រីមាស*




### បំណែងចែកសមតុល្យតាមប្រភេទផលិតផល




### បំណែងចែកសមតុល្យតាមប្រភេទរូបិយប័ណ្ណ




ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី
របាយការណ៍ប្រចាំឆ្នាំ ២០២០

# គុណភាពឥណទាន

គុណភាពឥណទាន ជារង្វាស់មួយដ៏សំខាន់របស់ទីផ្សារឥណទាន ក្នុងការបង្ហាញអំពីលទ្ធភាពនៃការបង់សង ឬហានិភ័យនៃផលប័ត្រ។ គុណភាពឥណទាន ត្រូវបានវាស់វែងដោយប្រើប្រាស់សន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺតលើសពី ៣០ ថ្ងៃ ដែលយើងហៅថា ៣០+ DPD ។

យើងឃើញថាសន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺតលើសពី ៣០ថ្ងៃ មានការកើនឡើងបន្តិច ដោយក្នុងនោះត្រីមាសទី២ មានការកើនឡើងខ្ពស់ជាងគេ។ កម្ចីអចលនទ្រព្យ មានសន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺតលើសពី ៣០ថ្ងៃ តិចជាងគេ រីឯកម្ចីលក្ខណៈបុគ្គលមានសន្ទស្សន៍ច្រើនជាងគេ។

**១.៦៩%**
នៃអត្រាឥណទានមិនដំណើរការលើសពី ៣០ថ្ងៃគិតត្រឹមឆ្នាំ២០២០

### សន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺតលើសពី ៣០ ថ្ងៃតាមត្រីមាស




### ភាគរយសន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺត (គិតមកដល់ខែធ្នូ ២០២០)



# ទំនាក់ទំនងដំណើរការឥណទាន

អ្នកប្រើប្រាស់កម្ចីជាមួយស្ថាប័នហិរញ្ញវត្ថុមានការកើនឡើងចម្រុះ។ អ្នកខ្ចីភាគច្រើនមានទំនាក់ទំនងជាមួយតែស្ថាប័នហិរញ្ញវត្ថុ ១ ប៉ុណ្ណោះ។ ខណៈពេលដែលអ្នកខ្ចីដែលមានគណនីតែមួយ គ្រប់គ្រងផលប័ត្រចំនួន ៦៧% អ្នកខ្ចីដែលមានគណនីលើសពី ១មានការកើនឡើង។ .

## ទំនាក់ទំនងអ្នកប្រើប្រាស់កម្ចីជាមួយស្ថាប័នហិរញ្ញវត្ថុ




## ភាគរយនៃអតិថិជនតាមប្រភេទចំនួនគណនី



# ស្ថានភាពទីផ្សារឥណទាន
# ក្រុមហ៊ុននៅកម្ពុជា

នៅក្នុងឆ្នាំ២០២០ មានការស្នើសុំឥណទានក្រុមហ៊ុនចំនួន ៣,៤៧៦ សំណើរ ស្មើនឹងសមតុល្យឥណទានសរុបចំនួន៥.៥៨ពាន់លាន។សន្ទស្សន៍នៃការបង់ប្រាក់សងត្រលប់វិញយឺតលើសពី ៣០ ថ្ងៃមានប្រមាណ ២.៣៧ភាគរយ ។ អ្នកប្រើប្រាស់ឥណទានក្រុមហ៊ុនមានចំនួន១,៣៣០រួមជាមួយគណនីចំនួន៥,៣១៥។ក្រុងភ្នំពេញមានចំនួនអ្នកខ្ចីឥណទានក្រុមហ៊ុនច្រើនជាងគេ បន្ទាប់មកគឺខេត្តសៀមរាប និងខេត្តកណ្តាល។

**ចំនួនអ្នកប្រើប្រាស់ឥណទាន**
១,៣៣០

**ចំនួនគណនីឥណទាន**
៥,៣១៥

**ចំនួនពាក្យស្នើសុំឥណទាន**
៣,៤៧៦

**ភាគរយនៃឥណទាន**
**មិនដំណើរការលើសពី ៣០ ថ្ងៃ (៣០ + DPD)**
២.៣៧%

**បំណែងចែកសមតុល្យតាមប្រភេទរូបិយប័ណ្ណ**



## ចំនួនគណនី




| | |
|---|---|
| តំបន់ទំនាប<br>៤,៧៥១ | តំបន់ទន្លេសាប<br>៣៨៨ |
| តំបន់ខ្ពង់រាប<br>១២៥ | តំបន់ឆ្នេរសមុទ្រ<br>៦១ |

*គណនី៨ ផ្សេងទៀតមកពីបរទេស*

## សមតុល្យឥណទានសរុប




| | |
|---|---|
| តំបន់ទំនាប<br>$៤.៩១ ពាន់លាន | តំបន់ទន្លេសាប<br>$០.២៥ ពាន់លាន |
| តំបន់ខ្ពង់រាប<br>$០.០៧ ពាន់លាន | តំបន់ឆ្នេរសមុទ្រ<br>$០.២៥ ពាន់លាន |

** សមតុល្យឥណទានចំនួន ៦២លានផ្សេងទៀតមក ពីបរទេស*

CBC

ក្រុមហ៊ុនឈានមុខគេ ក្នុងការផ្តល់នូវសេវាព័ត៌មានហិរញ្ញវត្ថុ
ឧបករណ៍វិភាគទិន្នន័យ និងរបាយការណ៍ឥណទាន
ទៅដល់ស្ថាប័នហិរញ្ញវត្ថុទាំងអស់ នៅក្នុងប្រទេសកម្ពុជា។

របាយការណ៍ប្រចាំឆ្នាំ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី
រាជធានីភ្នំពេញ ២០២០